មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

កំណត់ត្រាសង្ខេប

ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥

ស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្នុងឆ្នាំ២០១៤

មូលន័យសង្ខេប

បើទោះបីជាកិច្ចការពារអ្នកការពារសិទ្ធិមនុស្ស ("អ.ក.ស.ម")ស្ថិតនៅក្រោមការការពារដោយ កាតព្វកិច្ចច្បាប់អន្តរជាតិជាច្រើនដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") អ្នកការពារសិទ្ធិមនុស្សជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") នៅតែបន្តទទួលរងការគម្រាមកំហែងជាច្រើន រួមមានការចាប់ និងឃុំខ្លួនតាមអំពើចិត្ត ការប្រើហិង្សាលើរាងកាយ និងការធ្វើឃាត ការគម្រាម ការសម្លុតបំភ័យ និងការយាយី។ ភាពស្ងាក់ស្ងើររបស់រាជរដ្ឋាភិបាលកម្ពុជា("រដ្ឋាភិបាល") ក្នុងការការពារអ្នកការពារសិទ្ធិមនុស្ស ព្រមទាំងសកម្មភាពដ៏សកម្មរបស់រដ្ឋាភិបាលក្នុងការរឹតត្បិតសិទ្ធិរបស់ប្រជាពលរដ្ឋ បង្ហាញពីការបំពានកាតព្វកិច្ចរបស់រដ្ឋក្នុងការគោរព ការពារ និងដាក់កំហិតប្រកបដោយគ្រោះថ្នាក់ដល់បរិយាកាសបំពេញការងាររបស់ អ.ក.ស.ម ។

កំណត់ត្រាសង្ខេបនេះ ធ្វើការវាយតម្លៃពីស្ថានភាព អ.ក.ស.ម នៅប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៤ រួមទាំងការរឹតត្បិតលើសេរីភាពខាងការជួបប្រជុំ និងខាងការបញ្ចេញមតិ និងទម្រង់នៃការបំពារបំពានផ្សេងទៀត។ ព័ត៌មានដែលបានដាក់បញ្ចូលក្នុងកំណត់ត្រាសង្ខេបនេះ គឺយោងទៅតាមទិន្នន័យរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា("ម.ស.ម.ក")ដែលប្រមូលបាន ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង អ.ក.ស.ម ដែលថ្មីៗនេះបានវិវត្តទៅជាគម្រោងការពារសេរីភាពមូលដ្ឋាន[1] ដែលបានផ្តល់ការគាំទ្រដល់ អ.ក.ស.ម ដែលរងការគម្រាមកំហែង និងលើកកម្ពស់សិទ្ធិរបស់ពួកគាត់ ស្វះស្វែងធ្វើយ៉ាងណាឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាននៅក្នុងគោលនយោបាយរដ្ឋាភិបាល ការគោរព និងការអនុវត្តតាម ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។

[1] គម្រោងការពារសេរីភាពមូលដ្ឋាន ("គម្រោង") មានគោលបំណងកាត់បន្ថយទៅលើការរឹតត្បិតសេរីភាពមូលដ្ឋាន រួមមាន សេរីភាពខាងការបង្កើតសមាគម សេរីភាពខាងការជួបប្រជុំ និងសេរីភាពខាងការបញ្ចេញមតិ ដែលនៅតែបន្តកើតមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ជាពិសេសការរឹតត្បិតដល់អ្នកការពារសិទ្ធិមនុស្ស មេដឹកនាំសហជីព និងកម្មករ សកម្មជនសហគមន៍/ សកម្មជនលើបណ្តាញអ៊ីនធឺណែត/ សកម្មជននយោបាយ អ្នកកាសែត និងអ្នកតវ៉ាអហិង្សា។

ផ្នែកទី១ បរិយាយអំពីក្របខណ្ឌច្បាប់ក្នុងការការពារ អ.ក.ស.ម នៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ ព្រមទាំងរំលេចនូវកាតព្វកិច្ចរបស់រដ្ឋាភិបាលដើម្បីការពារ អ.ក.ស.ម។ ផ្នែកបន្ទាប់ នឹងបង្ហាញពីរបត់ និងគំរូនៃរឿងរ៉ាវដែលបានកើតឡើងជាក់ស្តែងនៅក្នុងឆ្នាំ២០១៤ រួមទាំងការវិភាគ និងករណីសិក្សាលើការប្រើប្រាស់កម្លាំងហួសប្រមាណរបស់កងសន្តិសុខទប់ទល់នឹងការតវ៉ា ការហាមឃាត់ទាំងស្រុងទៅលើការធ្វើបាតុកម្ម ការចាប់ខ្លួនអ្នកតវ៉ាតាមអំពើចិត្ត និងការបង្ខិតបង្ខំសកម្មជនឲ្យចុះហត្ថលេខាទៅលើកិច្ចសន្យាមិនចូលរួមក្នុងសកម្មភាពតវ៉ាផ្សេងទៀត ការយាយីតាមផ្លូវតុលាការ និងការដៅមុខសញ្ញាលើអ្នកការពារបរិស្ថាន និងអ្នកការពារសិទ្ធិដីធ្លី។ ចុងក្រោយនៃកំណត់ត្រានេះ នឹងធ្វើសេចក្តីសន្និដ្ឋានភ្ជាប់មកជាមួយនូវអនុសាសន៍ ដាក់ជូនរដ្ឋាភិបាល និងតុលាការ ដើម្បីធ្វើឲ្យស្ថានភាព អ.ក.ស.ម នៅកម្ពុជាមានភាពប្រសើរឡើង។ អនុសាសន៍ទាំងអស់នោះរួមមាន ៖

- ដាក់ពង្រាយកងកម្លាំងយោធាតែក្នុងស្ថានភាពធ្ងន់ធ្ងរពាក់ព័ន្ធនឹងបញ្ហាសន្តិសុខជាតិ និងបញ្ឈប់ការប្រើកងកម្លាំងសន្តិសុខខណ្ឌឲ្យយាមកាមនៅកន្លែងបាតុកម្ម
- ធានាថា មន្ត្រីអនុវត្តច្បាប់ទាំងអស់ដែលដាក់ឲ្យរក្សាសន្តិសុខនៅពេលធ្វើបាតុកម្ម បានទទួលការបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្ស និងគោរពតាមគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើកម្លាំងប្រដាប់អាវុធ និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់
- ធានាឲ្យមានការស៊ើបអង្កេតបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយផ្តន្ទាទោសជនដៃដល់ដោយស្ថាប័នឯករាជ្យ និងមិនលម្អៀង ធ្វើរបាយការណ៍អំពីការប្រើប្រាស់កម្លាំងហួសប្រមាណដោយមន្ត្រីអនុវត្តច្បាប់ និងកងសន្តិសុខឯកជនដែលអាជ្ញាធរមូលដ្ឋានបានជួលមកបម្រើការ ព្រមទាំងដាក់បង្ហាញលទ្ធផលនោះជាសាធារណៈ
- ធានាផ្តល់សំណងឲ្យមានប្រសិទ្ធិភាពដល់ជនរងគ្រោះ និងធានាថា រាល់ករណីរំលោភបំពាននិងអំពើហិង្សាប្រឆាំងនឹងអ្នកសារព័ត៌មានសកម្មជននយោបាយ អ្នកនយោបាយគណបក្សជំទាស់ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកសហជីព និងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀតមានការស៊ើបអង្កេតត្រឹមត្រូវ ហើយជនដៃដល់ត្រូវបាននាំយកមកផ្តន្ទាទោសដោយមិនគិតពីឋានៈរបស់ជននោះ
- ធានាការគោរពសិទ្ធិសេរីភាពខាងការជួបប្រជុំ ហើយបញ្ឈប់ជាផ្លូវការនូវការហាមប្រាមតាមអំពើចិត្តទាំងស្រុងចំពោះការជួបប្រជុំជាសាធារណៈ
- បញ្ឈប់នូវការអនុវត្តដែលបង្ខំឲ្យអ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋដែលអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានខាងការបញ្ចេញមតិ សេរីភាពខាងការជួបប្រជុំ ចុះហត្ថលេខាលើលិខិតដែលមានការរឹតត្បិតដល់សិទ្ធិរបស់ពួកគេដើម្បីជាថ្នូរទៅនឹងការដោះលែង ឬចៀសវាងការចោទប្រកាន់ ព្រមទាំងលុបចោលនូវលិខិតទាំងឡាយណាដែលបានចុះហត្ថលេខានាពេលកន្លងមក
- អនុវត្តជាបន្ទាន់នូវការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របទៅតាមគោលការណ៍ទីក្រុង ប៉ារីស

- បញ្ឈប់ការយាយីតាមប្រព័ន្ធតុលាការមកលើអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងអ្នកនយោបាយគណបក្សជំទាស់ ព្រមទាំងដោះលែងជាបន្ទាន់ដោយគ្មានលក្ខខ័ណ្ឌដល់អ្នកកំពុងជាប់ឃុំ ដែលត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសដោយសារហេតុផលនយោបាយ
- ឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់អ្នករាយការពិសេសអំពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋ (នៅឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានសរសេរសំណើទៅកាន់រដ្ឋាភិបាលដើម្បីមកធ្វើទស្សនកិច្ចផ្លូវរដ្ឋនៅកម្ពុជា)[2] ។

កំណត់ត្រាសង្ខេបនេះធ្វើឡើងដោយ ម.ស.ម.ក ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលិទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ក្របខ័ណ្ឌច្បាប់

ក្របខ័ណ្ឌច្បាប់អន្តរជាតិ

កិច្ចការពារអ្នកការពារសិទ្ធិមនុស្សស្ថិតនៅក្នុងក្របខ័ណ្ឌការពារតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលចែងនៅក្នុងលិខិតតុបករណ៍អន្តរជាតិដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាដើម។ លើសពីនេះទៅទៀត ក៏មានយន្តការពិសេសមួយចំនួនទៀតត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ក្នុងការផ្តល់ និងការពារសិទ្ធិរបស់រូបវន្តបុគ្គល និងអង្គការទាំងឡាយដែលធ្វើការការពារសិទ្ធិអ្នកដទៃ។

សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស ("សេចក្តីប្រកាសស្តីពី អ.ក.ស.ម")[3] គឺជាលិខិតតុបករណ៍អន្តរជាតិដំបូងតែមួយគត់ដែលចែងអំពីអ្នកការពារសិទ្ធិមនុស្ស។ បើទោះបីជាសេចក្តីប្រកាសនេះគ្មានលក្ខណៈចងជាកាតព្វកិច្ចច្បាប់ក្តី តែសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្សត្រូវបានអនុម័តជាឯកច្ឆន្ទ ដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិក្នុងឆ្នាំ ១៩៩៨ ក្នុងឱកាសរំលឹកខួបទី៥០នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។ ការអនុម័តជាឯកច្ឆន្ទនេះបានបង្ហាញនូវការបោះដំហានយ៉ាងសំខាន់ ឆ្ពោះទៅរកការទទួលស្គាល់ជាអន្តរជាតិចំពោះការងាររបស់អ្នកការពារសិទ្ធិមនុស្ស និងគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចការពារ អ.ក.ស.ម។ សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស មិនបង្កើតសិទ្ធិថ្មីនោះទេ ប៉ុន្តែទទួលស្គាល់សិទ្ធិក្នុងការលើកកម្ពស់

[2] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា "ទស្សនកិច្ចផ្លូវរដ្ឋ" http://goo.gl/Z1SD0r

[3] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ "សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ក្រុម និងសរីរាង្គសង្គម ដើម្បីលើកកម្ពស់ និងការពារ និងទទួលស្គាល់ជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន" (ថ្ងៃទី៨ ខែមីនា ឆ្នាំ ១៩៩៩) ឯកសារអង្គការសហប្រជាជាតិ A/RES/53/144 http://bit.ly/19w8LEm

និងទាមទារឲ្យមានកិច្ចការពារ និងទទួលស្គាល់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន[4] សិទ្ធិសេរីភាពខាងការបញ្ចេញមតិ[5] ការជួបប្រជុំដោយសន្តិវិធី[6] និងសិទ្ធិក្នុងការបង្កើត និងចូលរួមជាមួយអង្គការមិនមែនរដ្ឋាភិបាល សមាគម ឬក្រុមណាមួយ[7]។ ជាងនេះទៅទៀត សេចក្តីប្រកាសស្តីពី អ.ក.ស.ម ក៏បានលើកឡើងជាថ្មីម្តងទៀតពីតួនាទីជាក់លាក់សំខាន់ៗរបស់ អ.ក.ស.ម និងរដ្ឋ។ ក្រោយមក ការអនុម័តសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ [8] និងក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ[9] លើកឡើងសារជាថ្មីនូវសារៈសំខាន់នៃសិទ្ធិដែលមានចែងនៅក្នុងសេចក្តីប្រកាសស្តីពី អ.ក.ស.ម ហើយជំរុញឲ្យរដ្ឋអនុវត្តនូវកិច្ចការពារជាក់លាក់ដើម្បីធានាសុវត្ថិភាពរបស់ អ.ក.ស.ម។

សេចក្តីប្រកាសស្តីពី អ.ក.ស.ម ផ្តល់និយមន័យឲ្យ អ.ក.ស.ម ថា ជារូបវន្តបុគ្គល ឬក្រុម និងសមាគម ដែលធ្វើសកម្មភាពដើម្បីលុបបំបាត់អំពើហិង្សា នៃការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានរបស់មនុស្ស និងរូបវន្តបុគ្គល។[10] សិទ្ធិទាំងនេះអាចជាសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌ និងអាចគ្របដណ្តប់លើបញ្ហាផ្សេងៗទៀតដែលមានដូចជា ការរើសអើង និងការបណ្តេញចេញដោយបង្ខំជាដើម។ អ្នកការពារសិទ្ធិមនុស្សជាទូទៅមានដូចជា អ្នកដែលមានវិជ្ជាជីវៈផ្នែកសិទ្ធិមនុស្ស អ្នកសារព័ត៌មាន មេធាវីតំណាងសហគមន៍ តែទោះជាយ៉ាងណានៅមានបុគ្គលជាច្រើនទៀតមានគុណសម្បត្តិជា អ.ក.ស.ម។ [11] ដើម្បីអាចចាត់ថ្នាក់ជាអ្នកការពារសិទ្ធិមនុស្សបានទាល់តែ បុគ្គលទាំងនោះត្រូវតែអហិង្សា ហើយត្រូវទទួលស្គាល់ភាពជាសាកលនៃសិទ្ធិមនុស្ស។[12] អ្នកការពារសិទ្ធិមនុស្សបំពេញការងារផ្សេងៗពីគ្នា ដូចជា ចងក្រងការរំលោភសិទ្ធិមនុស្ស ផ្តល់ការអប់រំ ឬ

---

[4] សូមមើលមាត្រា១

[5] សូមមើលមាត្រា៦

[6] សូមមើលមាត្រា៥ (ក)

[7] សូមមើលមាត្រា៥ (ខ) និង(គ)

[8] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ " ការលើកកម្ពស់សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ក្រុម និងសរីរាង្គសង្គម ដើម្បីលើកកម្ពស់ និងការពារ និងទទួលស្គាល់ជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន" (ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១១) ឯកសារអង្គការសហប្រជាជាតិ A/RES/66/164, http://bit.ly/1qiUIfU.

[9] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "កិច្ចការពារអ្នកការពារសិទ្ធិមនុស្ស " (ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១០) ឯកសារអង្គការសហប្រជាជាតិ A/HRC/13/L.24, http://bit.ly/1tXQIlo; សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "ការលើកកម្ពស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានតាមរយៈការយល់ដឹងកាន់តែប្រសើរឡើងនៃគុណតម្លៃមនុស្សជាតិ" (ថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១១) ឯកសារអង្គការសហប្រជាជាតិ A/HRC/RES/16/3http://goo.gl/kfaf8Z; ក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ "ការពារអ្នកការពារសិទ្ធិមនុស្ស" (ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៣) ឯកសារអង្គការសហប្រជាជាតិ A/HRC/22/L.13, http://bit.ly/YXSF7Y.

[10] សេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ (លេខ១) កថាខ័ណ្ឌទី ៤ នៃបុព្វកថា

[11] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ សលាកបត្រព័ត៌មាន លេខ ២៩ ៖ អ្នកការពារសិទ្ធិមនុស្ស ការការពារសិទ្ធិដើម្បីការពារសិទ្ធិមនុស្ស (ខែមេសា ឆ្នាំ២០០៤) http://goo.gl/EnVkvy.

[12] ដូចខាងលើ

ការបណ្តុះបណ្តាលពីសិទ្ធិមនុស្ស ធ្វើការតវ៉ាដើម្បីទាមទារឲ្យមានការយកចិត្តទុកដាក់លើបញ្ហាបរិស្ថាន ការលើកកម្ពស់ការយល់ដឹងពីសិទ្ធិមនុស្ស។ល។[13]

លើសពីនេះទៅទៀត ដើម្បីបង្ហាញពីសិទ្ធិរបស់ អ.ក.ស.ម សេចក្តីប្រកាសស្តីពី អ.ក.ស.ម ក៏បញ្ជាក់ផងដែរនូវតួនាទីរបស់រដ្ឋាភិបាលដើម្បីធានាការការពារដល់ អ.ក.ស.ម។ យោងមាត្រា ១២ (២) អាជ្ញាធរពាក់ព័ន្ធត្រូវតែការពារ អ.ក.ស.ម ពីការចាប់ខ្លួន អំពើហិង្សា ការគំរាមកំហែង ការសងសឹក និងការរើសអើង ដែលកើតចេញពីសកម្មភាពការពារសិទ្ធិមនុស្សរបស់ពួកគេ ហើយក៏បានសង្កត់ធ្ងន់ផងដែរថា អ.ក.ស.ម គួរតែត្រូវបានការពារដោយច្បាប់ជាតិ។ [14] សេចក្តីប្រកាសនោះក៏បានគូសបញ្ជាក់ដែរថា អ.ក.ស.ម មានសិទ្ធិប្រឆាំងទៅនឹងសកម្មភាពទាំងឡាយរួមទាំង ភាពអសកម្ម និងការប្រព្រឹត្តដោយរដ្ឋដែលជាលទ្ធផលនាំឲ្យមានការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។[15]

យន្តការបន្ថែម រួមចំណែកក្នុងការការពារសិទ្ធិមនុស្សនៅថ្នាក់អន្តរជាតិ។ កាលពីឆ្នាំ២០០០ គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ[16] បានបង្កើតឲ្យមានអ្នករាយការណ៍ពិសេសអំពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស (“អ្នករាយការណ៍ពិសេស”) ដែលផ្នែកមួយនៅក្នុងអាណត្តិរបស់ខ្លួនគឺជួយដល់ការអនុវត្តសេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស។[17] ក្នុងចំណោមការងារជាច្រើន អ្នករាយការណ៍ពិសេសអាចទទួលព័ត៌មាន និងពាក្យបណ្តឹងបុគ្គល[18] អំពីការរំលោភសិទ្ធិ អ.ក.ស.ម និងអាចទាក់ទងទៅរដ្ឋសមាជិកដែលពាក់ព័ន្ធក្នុងករណីទាំងនេះ។ អ្នករាយការណ៍ពិសេសក៏មានបេសកកម្មធ្វើទស្សនកិច្ចផ្លូវរដ្ឋទៅកាន់ប្រទេសណាមួយ ដើម្បីស៊ើបអង្កេតពីស្ថានភាព អ.ក.ស.ម ហើយបង្ហាញរបាយការណ៍ប្រចាំឆ្នាំជូនក្រុមប្រឹក្សាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។[19] កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ សេចក្តីសម្រេចដំបូងបង្អស់ស្តីពី អ.ក.ស.ម ត្រូវបានអនុម័តដោយគណៈកម្មាធិការទី៣ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ដែលលើកឡើងអំពីហានិភ័យជាក់លាក់ ការរើសអើង

---

[13] ដូចខាងលើ

[14] ដូចខាងលើ មាត្រា១២ (៣)

[15] ដូចខាងលើ

[16]គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិត្រូវបានជំនួសដោយ ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឆ្នាំ ២០០៦ ។ សូមមើល អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស “សហប្រជាជាតិអង្គការសិទ្ធិមនុស្សប្រឹក្សាក្រុម” http://goo.gl/dr0bl.

[17]លោកស្រី ម៉ាហ្គារ៉ែត ស៊ីកាយ៉ា បានកាន់ដំណែងនេះចាប់ពីឆ្នាំ២០០៨ ដល់ ២០១៤ ហើយត្រូវបានជំនួសដោយ មីស៊ែល ហ្វូសត៍ ដែលត្រូវបានតែងតាំងកាលពីខែមិថុនា ឆ្នាំ២០០៤។ សូមមើល អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស “អ្នករាយការណ៍ពិសេសស្តីពីអ្នកការពារសិទ្ធិមនុស្ស” http://bit.ly/1q1Hfc6.

[18] បណ្តឹងរបស់បុគ្គលដែលចោទប្រកាន់លើសិទ្ធិរបស់អ្នកការពារសិទ្ធិមនុស្សអាចត្រូវដាក់ជូនអ្នករាយការណ៍ពិសេស។ សូមមើលអង្គសហប្រជាការជាតិស្តីពីសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស “បណ្តឹង៣ក្យដាក់ការ” http://bit.ly/1C4DJEi

[19]អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស “ទស្សនកិច្ចផ្លូវរដ្ឋ” http://goo.gl/Z1SD0r

និងអំពើហិង្សាដែលអ្នកការពារសិទ្ធិមនុស្សជាស្ត្រីត្រូវបានប្រឈម។[20]

បន្ថែមពីលើយន្តការដែលមានស្រាប់សម្រាប់ អ.ក.ស.ម ការអភិវឌ្ឍន៍ជាទូទៅខាងផ្នែកសិទ្ធិមនុស្សក៏អាចការពារ អ.ក.ស.ម ផងដែរ។ ឧទាហរណ៍ គោលការណ៍ទីក្រុងប៉ារីស[21] ដែលអនុម័តដោយអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៣ ជំរុញឲ្យមានការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិដែលមានសមាសភាពចម្រុះ និងឯករាជ្យ។ ស្ថាប័នទាំងនេះជាការិយាល័យទទួលបន្ទុកការពារសិទ្ធិមនុស្ស ហើយក៏ជាឧបករណ៍បន្ថែមដើម្បីការពារ អ.ក.ស.ម ផងដែរ។

ក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់

នៅថ្នាក់តំបន់ អង្គការជាច្រើនបានបង្កើតយន្តការពិសេសដើម្បីបំពេញបន្ថែមក្របខ័ណ្ឌការពារជាអន្តរជាតិ ដើម្បីបង្ហាញការទទួលស្គាល់កាន់តែទូលំទូលាយពីសារៈសំខាន់នៃការងាររបស់ អ.ក.ស.ម។

ជាងនេះទៅទៀត អង្គការនៅថ្នាក់តំបន់ទាំងអស់បានបង្ហាញពីសកម្មភាពពាក់ព័ន្ធសកម្មៗនឹងកិច្ចការពារ អ.ក.ស.ម។ កាលពីឆ្នាំ២០០៨ គណៈកម្មាធិការក្រុមប្រឹក្សារដ្ឋមន្ត្រីអឺរ៉ុប បានបញ្ជាក់ជាថ្មីពីសារៈសំខាន់នៃកិច្ចការពារ អ.ក.ស.ម និងអំពាវនាវឲ្យរដ្ឋភាគីពិចារណាពង្រឹងសមត្ថភាពនៃគណៈកម្មការឯករាជ្យ ស្ថាប័នសិទ្ធិមនុស្សជាតិ ឬបុគ្គលឯករាជ្យដោះស្រាយពាក្យបណ្តឹងរបស់ អ.ក.ស.ម ពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិរបស់គេ។[22] ជាងនេះទៅទៀត សហភាពអឺរ៉ុប និងអង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការណ៍អឺរ៉ុប បានបង្កើតគោលការណ៍ណែនាំស្តីពី អ.ក.ស.ម។ គោលការណ៍ណែនាំសហភាពអ៊ឺរ៉ុបនោះមិនត្រឹមតែអំពាវនាវដល់បេសកកម្មរបស់សហភាពអឺរ៉ុបក្នុងការផ្តល់ជំនួយជាក់ស្តែងដល់សកម្មជនដែលប្រឈមនឹងហានិភ័យនោះទេ ប៉ុន្តែក៏ជួយឲ្យសហភាពអឺរ៉ុបផ្តល់ជំនួយដល់ អ.ក.ស.ម តាមរយៈទំនាក់ទំនងជាមួយរដ្ឋដែលមិនមែនជាសមាជិករបស់សហភាពអឺរ៉ុប និងតាមរយៈកិច្ចប្រជុំពហុភាគី ឧទាហរណ៍ តាមរយៈលើកឡើងពីស្ថានភាព អ.ក.ស.ម នៅក្នុងកិច្ចពិភាក្សានយោបាយ និងតស៊ូមតិដល់ប្រទេសទាំងនោះ ឲ្យបង្កើតច្បាប់នៅក្នុងប្រទេសរបស់ខ្លួន

---

[20] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ " ការលើកកម្ពស់សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ក្រុម និងសរីរាង្គសង្គម ដើម្បីលើកកម្ពស់ និងការពារ និងទទួលស្គាល់ជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ៖ ការពារ អ.ក.ស.ម ជាស្ត្រី" (ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣) ឯកសារអង្គការសហប្រជាជាតិ A/RES/68/181, http://goo.gl/yz4xwt

[21] សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ "គោលការណ៍ពាក់ព័ន្ធទៅនឹងគោលជំហររបស់ស្ថានប័នជាតិ (គោលការណ៍ទីក្រុងប៉ារីស)" (ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣) ឯកសារអង្គការសហប្រជាជាតិ A/RES/48/134, http://goo.gl/nj0h8P.

[22] ក្រុមប្រឹក្សាគណៈកម្មាធិការរដ្ឋមន្ត្រីអឺរ៉ុប "សេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការរដ្ឋមន្ត្រីអឺរ៉ុបអំពីក្រុមប្រឹក្សាសកម្មភាពអឺរ៉ុប ដើម្បីធ្វើឲ្យប្រសើរឡើងដល់កិច្ចការពារ អ.ក.ស.ម និងលើកកម្ពស់សកម្មភាពរបស់ពួកគេ" (ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៨) http://bit.ly/12kSwNi.

ដោយអនុលោមតាមសេចក្តីប្រកាស ស្តីពី អ.ក.ស.ម។[23] ដូចគ្នាដែរ គោលការណ៍ណែនាំរបស់អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការណ៍អឺរ៉ុប ស្តីពីកិច្ចការពារ អ.ក.ស.ម ក៏អំពាវនាវដល់សមាជិករបស់អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការណ៍អឺរ៉ុបឲ្យបង្កើតយន្តការការពារ អ.ក.ស.ម ទាំងនៅក្នុងបូរណភាពទឹកដីរបស់ខ្លួន និងនៅប្រទេសទីបីតាមរយៈទំនាក់ទំនងការទូត។[24]

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (“អាស៊ាន”) ដើរតាមក្រោយអង្គការថ្នាក់តំបន់ផ្សេងទៀតពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស ហើយនៅក្នុងក្របខ័ណ្ឌនេះមិនបានផ្តល់កិច្ចការពារពេញលេញដល់អ្នកការពារសិទ្ធិមនុស្សក្នុងតំបន់របស់ខ្លួន។ តាមពិតទៅ អាស៊ាន មានការយឺតយ៉ាវក្នុងការបង្កើតឲ្យមានស្ថាប័នសិទ្ធិមនុស្សនៅក្នុងរចនាសម្ព័ន្ធរបស់ខ្លួន ៖ គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្ស បានចាប់ដំណើរការនៅឆ្នាំ២០០៩ ហើយមិនមានបទបញ្ញត្តិជាក់លាក់ណាមួយចែងពីសិទ្ធិអំណាចក្នុងការទទួលពាក្យបណ្តឹង និងការស៊ើបអង្កេតពីករណីរំលោភសិទ្ធិមនុស្សនោះទេ។ ជាងនេះទៅទៀត គណៈកម្មការអន្តររដ្ឋាភិបាលស្តីពីសិទ្ធិមនុស្ស មិនបានបង្កើតឲ្យមានស្ថាប័នស្វយ័តណាមួយសម្រាប់អ្នកការពារសិទ្ធិមនុស្ស ហើយសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន [25] ត្រូវបានអនុម័តកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ ពុំមានបញ្ញត្តិណាមួយចែងពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សឡើយ។

<u>ក្របខ័ណ្ឌច្បាប់ជាតិ</u>

ច្បាប់ក្នុងស្រុករបស់ប្រទេសកម្ពុជា មិនបានផ្តល់នូវការការពារជាក់លាក់ដល់អ្នកការពារសិទ្ធិមនុស្សឡើយ បើទោះបីជារដ្ឋធម្មនុញ្ញ[26] ការពារសេរីភាពមូលដ្ឋាន ហើយនៅក្នុងមាត្រា ៣១ គឺទទួលស្គាល់សិទ្ធិមនុស្ស ដូចមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានា។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញក៏បានចែងថា *“ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ”*[27] មាត្រា ៣៥ ផ្តល់ឲ្យប្រជាពលរដ្ឋនូវ " *“សិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាព នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ”*[28] ហើយ

---

[23] ក្រុមប្រឹក្សាក្រុមការងារបស់សហភាពអឺរ៉ុបស្តីពីកិច្ចការទូទៅ និងការវាយតម្លៃ (other than Schengen) (GENVAL), គោលការណ៍" ណែនាំរបស់សហភាពអឺរ៉ុបស្តីពីអ្នកការពារសិទ្ធិមនុស្ស ដែលបានបង្កើតឡើងដើម្បីធានាដល់កិច្ចការពារ អ.ក.ស.ម (ថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០០៨) http://goo.gl/SWZr5x.

[24] អង្គការដើម្បីសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE គោលការណ៍ណែនាំស្តីពីអ្នកការពារសិទ្ធិមនុស្ស” (ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ http://www.osce.org/odihr/119633?download=true

[25] សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ "សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ាន” (ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២) http://bit.ly/1tF3Vl1.

[26] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា http://cambodia.ohchr.org/klc_pages/KLC_files/section_001/section_01_01_ENG.pdf

[27] ដូចខាងលើ មាត្រា៤១

[28] ដូចខាងលើ មាត្រា៣៥

មាត្រា ៣៧ ផ្តល់នូវ *"សិទ្ធិធ្វើកូដកម្ម និង ធ្វើបាតុកម្មដោយសន្តិវិធី"។*[29] កាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិគឺមិនត្រឹមតែមានចែងនៅក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញប៉ុណ្ណោះទេ ប៉ុន្តែការអនុវត្តជាក់ស្តែងគឺត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា[30] កាលពីឆ្នាំ២០០៧ ដែលបានបញ្ជាក់ថា សន្ធិសញ្ញាអន្តរជាតិអាចយកមកអនុវត្តបានចំពោះមុខតុលាការ ដូច្នេះពុំមានច្បាប់ណាត្រូវបានប្រើប្រាស់ដោយផ្ទុយពីរដ្ឋធម្មនុញ្ញ ឬសន្ធិសញ្ញាទាំងឡាយពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលកម្ពុជាគឺជារដ្ឋភាគីនោះឡើយ។[31] ក្រៅពីបញ្ញត្តិទាំងនេះ ពុំមានយន្តការសិទ្ធិមនុស្សណាមួយដែលអាចការពារអ្នកការពារសិទ្ធិមនុស្សឲ្យរួចផុតពីការរំលោភបំពាន ឬធានាសងជំងឺចិត្ត និងការខូចខាតឡើយ។

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៤ មានរដ្ឋចំនួន៩[32] បានផ្តល់អនុសាសន៍ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើឲ្យប្រសើឡើងចំពោះកិច្ចការពារអ្នកការពារសិទ្ធិមនុស្ស ឧទាហរណ៍ ការចូលរួមក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិជាមួយអ្នកការពារសិទ្ធិមនុស្ស ឆ្លើយតបទៅនឹងបទដ្ឋានសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ ហើយបញ្ឈប់សកម្មភាពសម្តុតបំភ័យ ឬយាយីអ្នកការពារសិទ្ធិមនុស្ស។[33] រដ្ឋាភិបាលបានទទួលយកអនុសាសន៍ភាគច្រើនរួមទាំងអនុសាសន៍៧ ដែលពាក់ព័ន្ធដោយផ្ទាល់នឹង អ.ក.ស.ម ដូចជា អនុសាសន៍របស់សាធារណៈរដ្ឋឆេក ដែលបានស្នើឲ្យមានការកែប្រែក្រមព្រហ្មទណ្ឌ និងច្បាប់ផ្សេងទៀតដើម្បីឲ្យស្របតាមស្តង់ដារអន្តរជាតិនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងការពារការយាយីដល់ អ.ក.ស.មអ្នកសារព័ត៌មាន និងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងអនុសាសន៍របស់ប្រទេសអូទ្រីសធ្វើឲ្យមានការគោរព និងការពារសិទ្ធិរបស់ អ.ក.ស.ម និងអ្នកសារព័ត៌មានដើម្បីបំពេញការងារដោយគ្មានការរារាំង ការសម្តុតបំភ័យ ឬយាយី។ ប៉ុន្តែទោះជាយ៉ាងណាក្តី កម្ពុជាមិនគាំទ្រអនុសាសន៍របស់ប្រទេសទុយន៏ស៊ី ដែលសុំឲ្យមានការធានាបរិយាកាសប្រសើរជាងមុនសម្រាប់សកម្មភាពរបស់អ្នកការពារសិទ្ធិមនុស្ស ហើយក៏មិនទទួលយកអនុសាសន៍របស់ប្រទេសប៉ូឡូញ សុំឲ្យមានការការពារ អ.ក.ស.ម ពីការយាយី និងការចាប់ខ្លួនតាមអំពើចិត្ត ព្រមទាំងលុបចោលរាល់ការរឹតត្បិតចំពោះការតវ៉ាដោយសន្តិវិធី។[34] ទោះជាយ៉ាងណាក្តី រាជរដ្ឋាភិបាលកម្ពុជាមិនបានបង្កើតគោលការណ៍ណាមួយ ឬចាត់វិធានការណាមួយជាក់លាក់ដើម្បីការពារ អ.ក.ស.ម ឡើយ។

---

[29] ដូចខាងលើ មាត្រា៣៧

[30] ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ ,ដូចខាងលើ មាត្រា ១៣៦

[31] ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្តដា ឆ្នាំ២០០៧)

[32] អៀរឡង់, សាធារណៈរដ្ឋឆេក, អូទ្រីស, ឈីលី , នូវែលសេឡង់,បែលហ្ស៊ិក, បារាំង, , អាល្លឺម៉ង់ ព័រទុយហ្គាល់ និង ទុយន៏ស៊ី បានផ្តល់អនុសាសន៍មកលើប្រធានបទនេះ។ សូមមើល ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់ក្រុមការងារស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់មកលើប្រទេសកម្ពុជា" ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ ឯកសារអង្គការសហប្រជាជាតិ A/HRC/26/16, http://goo.gl/XzZk9M.

[33] ដូចខាងលើ

[34] ដូចខាងលើ

កម្ពុជាមានគណៈកម្មាធិការបីដែលធ្វើការពាក់ព័ន្ធនឹងសិទ្ធិមនុស្សគឺ គណៈកម្មាការសិទ្ធិមនុស្សរបស់ព្រឹទ្ធសភា គណៈកម្មាការសិទ្ធិមនុស្សរបស់រដ្ឋសភា និងគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមគណៈកម្មាធិការទាំងបី គ្មានគណៈកម្មាធិការណាមួយដែលឯករាជ្យ ឬស្វយ័តនោះទេ គណៈកម្មាធិការទាំងនោះត្រូវទទួលរងឥទ្ធិពលនយោបាយ និងបន្ទុះបង្អាក់សមត្ថភាពរបស់ពួកគេក្នុងការអនុវត្តតួនាទីឲ្យមានប្រសិទ្ធភាព។ [35] តាមរយៈសន្និសីទស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិក្នុងឆ្នាំ២០០៦ រដ្ឋាភិបាលបានប្តេជ្ញាចិត្តបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិដោយយោងលើគោលការណ៍ទីក្រុងប៉ារីស ពហុនិយម និងឯករាជ្យ ព្រមទាំងបង្កើតក្រុមការងាររួមរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ [36] ក្នុងអំឡុងពេលនៃការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់របស់កម្ពុជា មានប្រទេសចំនួន១០[37] បានផ្តល់អនុសាសន៍ថា កម្ពុជាត្រូវបង្កើនល្បឿនការបង្កើតស្ថាប័ននេះ។ បើទោះជាយ៉ាងនេះក្តី ច្បាប់នេះស្ថិតនៅក្នុងដំណាក់កាលព្រាងនៅឡើយ។

ម្យ៉ាងទៀត រដ្ឋាភិបាលនៅមិនទាន់បានផ្តល់សច្ចាប័នលើ ពិធីសារបន្ថែមទីមួយលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពាក់ព័ន្ធនឹងការទទួលយកនីតិវិធីបណ្តឹងបុគ្គលដែលទទួលស្គាល់សិទ្ធិអំណាចរបស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិដើម្បីទាក់ទងជាមួយជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សនៅឡើយដែរ។

ការចងក្រងករណីអំពីការរឹតត្បិតលើអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា

ជាទូទៅអ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ប្រឈមនឹងគ្រោះថ្នាក់ជាច្រើនដែលមិនអាចរំពឹងទុកបានដូចជា ការគម្រាមកំហែង ការវាយដំ ការសម្លាប់ និងការយាយីតាមផ្លូវតុលាការដូចជា ការចាប់ខ្លួនតាមអំពើចិត្ត និងការឃុំខ្លួនខុសច្បាប់។ នៅក្នុងបរិបទនៃកង្វះខាតក្របខ័ណ្ឌការពារជាសាធារណៈ ដូច្នេះសង្គមស៊ីវិលនៅតែជាតួអង្គសំខាន់ក្នុងការចងក្រងករណីរំលោភបំពាន និងការពារអ្នកការពារសិទ្ធិមនុស្ស។

ចាប់តាំងពីអនុវត្តគម្រោងអ្នកការពារសិទ្ធិមនុស្សកាលពីឆ្នាំ២០១១មក ម.ស.ម.ក តែងតែទទួលបានសំណើសុំជំនួយពីអ្នកការពារសិទ្ធិមនុស្សដែលប្រឈមនឹងហានិភ័យ។ ដូច្នេះ ម.ស.ម.ក បានចងក្រងរាល់ករណីរំលោភបំពានលើ អ.ក.ស.ម និងឧបសគ្គជាច្រើនទៀតដែលអ្នកការពារសិទ្ធិមនុស្សជួបប្រទះ តាមរយៈការប្រមូលព័ត៌មានទាក់ទងនឹងប្រភេទនៃការគម្រាមកំហែង ជនដៃដល់ និងផលជះលើការគាំទ្រដែល ម.ស.ម.ក ផ្តល់ឲ្យ។ ទិន្នន័យទាំងនេះផ្តែកទាំងស្រុងទៅលើអ្នកការពារសិទ្ធិមនុស្ស

---

[35] ម.ស.ម.ក សលាកប័ត្រព័ត៌មាន "កម្រងអត្ថបទស្ថាប័ន ៖ ស្ថាប័នសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា" (ខែមីនា ឆ្នាំ២០១២) http://goo.gl/VNq21u

[36] វេទិកាអាស៊ីប៉ាស៊ីហ្វិក "សន្និសីទស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សថ្នាក់ជាតិនៅកម្ពុជា" (ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦) http://bit.do/YFMn

[37] ឈីលី មីយ៉ាន់ម៉ា សែប អេហ្ស៊ីប ឥណ្ឌា ថៃ ម៉ាឡេស៊ី ម៉ារ៉ុក ប៉ាគីស្ថាន និងអូស្ត្រាលី ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់ក្រុមការងារស្តីពីការត្រួតពិនិត្យជាសកលតាមពេលវេលាកំណត់មកលើប្រទេសកម្ពុជា" ទំព័រ ៣២

ដែល ម.ស.ម.ក ការគាំទ្រតាមរយៈថវិការបស់គម្រោង និងធ្វើបច្ចុប្បន្នភាពលើករណីនីមួយៗចាប់តាំងពី ម.ស.ម.ក ចេញរបាយការណ៍មួយស្តីពី "ការពារអ្នកការពារសិទ្ធិមនុស្ស" កាលពីឆ្នាំ ២០១៣។ [38] ប៉ុន្តែទិន្នន័យទាំងអស់នេះមិនត្រូវបានចាត់ទុកថាជាករណីទាំងមូលដែលតំណាងឲ្យចំនួនអ្នកការពារសិទ្ធិមនុស្សទាំងអស់នៅកម្ពុជានោះទេ។



ក្រាហ្វទី ១ ៖ ប្រភេទការគម្រាមកំហែងប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា

នៅចុងឆ្នាំ២០១៤ គម្រោងបានផ្តល់ជំនួយចំនួន ៣៤ករណីដែលសរុបមានមនុស្ស ១៧១នាក់។ ក្នុងនោះ ៩១% នៃអ.ក.ស.ម បានទទួលរងការយាយីពីតុលាការរួមទាំងការចាប់ខ្លួនតាមអំពើចិត្ត ការឃុំខ្លួនខុសច្បាប់ និងការដាក់សម្ពាធឲ្យចុះហត្ថលេខាប្តេជ្ញាថា ពួកគេនឹងមិនចូលរួមបាតុកម្មនៅថ្ងៃក្រោយ(ក្រាហ្វទី ១)។ ចំណែក ៩% ទៀត គឺរងការបណ្តេញចេញដោយបង្ខំ ការបំពារបំពានលើរាងកាយ ឬត្រូវបានឃ្លាំមើលពេលធ្វើដំណើរ។ អ.ក.ស.ម ម្នាក់រងការគម្រាមសម្លាប់ និង ៦ នាក់ផ្សេងទៀតរងការគម្រាមជាច្រើនប្រភេទ។



[38] របាយការណ៍របស់ ម.ស.ម.ក "ការពារអ្នកការពារសិទ្ធិមនុស្ស ៖ សន្តិសុខដល់អ្នកការពារសិទ្ធិមនុស្សកម្ពុជា" (ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣) http://goo.gl/a61ulG

ក្រាហ្វទី ២ ៖ ប្រភេទជំនួយដែលផ្តល់ជូនបុគ្គលតាមរយៈមូលនិធិអ្នកការពារសិទ្ធិមនុស្ស

ជំនួយដែលគម្រោងផ្តល់ឲ្យ គឺមានលក្ខណៈខុសៗគ្នាអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃករណីនីមួយៗ។ ម.ស.ម.ក ធ្វើការតស៊ូមតិឲ្យ អ.ក.ស.ម មួយចំនួន ឧទាហរណ៍ដូចជា ការចេញផ្សាយនូវសេចក្តីថ្លែងការណ៍រួមដើម្បីលើកកម្ពស់ការយល់ដឹង និងបង្កើនការដាក់សម្ពាធទៅលើរដ្ឋាភិបាលឲ្យចាត់វិធានការ។ អ.ក.ស.ម ផ្សេងទៀតទទួលបាននូវជំនួយជាក់ស្តែង ដែលរួមមាន ថ្លៃអាហារ ជំនួយផ្នែកសុវត្ថិភាព និងសោហ៊ុយធ្វើដំណើរ។ មេធាវីដាប់កិច្ចសន្យារបស់ ម.ស.ម.ក ផ្តល់ជំនួយផ្នែកច្បាប់ដល់ អ.ក.ស.ម ជាច្រើននាក់ ហើយ ម.ស.ម.ក ក៏បានតាមដានសកម្មភាពរបស់ អ.ក.ស.ម ផ្សេងទៀតក្នុងករណីថាហានិភ័យដែលពួកគេប្រឈមមានការកើនឡើង។ អ.ក.ស.ម ភាគច្រើនទទួលជំនួយច្រើនប្រភេទដូចជា ជំនួយផ្នែកច្បាប់ និងជំនួយមនុស្សធម៌ដើម្បីគាំទ្រឲ្យមានការតស៊ូមតិជាសាធារណៈ។ សូមមើលក្រាហ្វទី ២ ខាងលើ។



ក្រាហ្វទី ៣ ៖ បង្ហាញពីការងារ អ.ក.ស.ម និងចំនួនករណី អ.ក.ស.ម ថ្មីក្នុងឆ្នាំ២០១៤

អ្នកការពារសិទ្ធិមនុស្សបានចូលរួមចំណែកក្នុងកិច្ចការជាច្រើនផ្នែក រួមមានផ្នែកការពារបរិស្ថាន ការពារសិទ្ធិលំនៅស្ថាន សារព័ត៌មាន អភិរក្សធនធានធម្មជាតិជាដើម។ ទោះជាយ៉ាងណាក៏ដោយ ដូចបានបង្ហាញនៅក្នុង ក្រាហ្វទី ៣ អ្នកការពារសិទ្ធិមនុស្សភាគច្រើនដែលទទួលបានការគាំទ្រពី ម.ស.ម.ក ធ្វើការពាក់ព័ន្ធនឹងសិទ្ធិការងារមាន (៣៧%) សិទ្ធិដីធ្លីមាន (២៥%) ការតវ៉ាដោយសន្តិវិធីមាន (១៦%) និងសកម្មជននយោបាយ (១៥%)។

យោងតាមទិន្នន័យដែលបានប្រមូល ម.ស.ម.ក អាចកំណត់នូវរបត់ និងគំរូនៃការរំលោភសិទ្ធិមនុស្ស និងឧបសគ្គដែល អ.ក.ស.ម ប្រឈមក្នុងពេលបំពេញការងាររបស់ពួកគេនៅក្នុងឆ្នាំ២០១៤ ។ កាលពីដើមឆ្នាំ២០១៤ កន្លងទៅបង្ហាញឲ្យឃើញថា រដ្ឋាភិបាលនៅតែបន្តប្រើប្រាស់កម្លាំងហួសប្រមាណបង្ក្រាបអ្នកតវ៉ា ដែលការប្រើកម្លាំងនេះបានកើនឡើងខ្លាំងក្នុងខែឧសភាពាក់ព័ន្ធនឹងការធ្វើ

បាតុកម្មរបស់កម្មករកាត់ដេរ ហើយជាលទ្ធផល ម.ស.ម.ក ក៏ឃើញនូវសន្ទុះកើនឡើង នៃអ្នកការពារសិទ្ធិមនុស្សផងដែរ។

ករណីខាងក្រោមបង្ហាញឲ្យឃើញពីរបៀបដែល អាជ្ញាធររដ្ឋ និងឧកញ៉ាដែលមានអំណាចបានបន្តសកម្មភាពរំលោភបំពានច្បាប់ជាតិ និងអន្តរជាតិ បណ្តាលឲ្យមានការរឹតត្បិតបរិយាកាសការងាររបស់អ្នកការពារសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

ការបង្ក្រាបទៅលើសេរីភាពខាងការបញ្ចេញមតិ និងខាងការជួបប្រជុំ[39]

ក្នុងឆ្នាំ២០១៤ គឺជាឆ្នាំដែលកត់សម្គាល់ឃើញថា មានការរំលោភបំពានធ្ងន់ធ្ងរមកលើសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំនៅទូទាំងប្រទេស។ ការរំលោភបំពានកន្លងមក គឺការប្រើកម្លាំងហួសប្រមាណរបស់កងកម្លាំងសន្តិសុខ បង្ក្រាបទៅលើអ្នកតវ៉ា ការហាមឃាត់មិនអើសមុខមកលើការតវ៉ា និងឧទាហរណ៍មួយចំនួននៃ ការចាប់ខ្លួនបាតុករតាមអំពើចិត្ត ហើយក្រោយមកត្រូវបានបង្ខំឲ្យចុះហត្ថលេខាដោយសន្យាមិនចូលរួមក្នុងការតវ៉ាតទៅទៀត។

ការប្រើប្រាស់កម្លាំងហួសប្រមាណបង្ក្រាបអ្នកតវ៉ា នៅចុងឆ្នាំ២០១៣ រួមមានទាំងការប្រើកាំភ្លើងបាញ់សម្លាប់អ្នកតវ៉ា [40] ហើយគួរឲ្យសោកស្តាយដែលទង្វើនេះបានបន្តរហូតមកដល់ដើមឆ្នាំ ២០១៤ ទៀត។ អំឡុងពេល ៣ថ្ងៃដំបូងនៃដើមខែ មករា ឆ្នាំ២០១៤ កងកម្លាំងនគរបាលបានបង្ក្រាបទៅលើក្រុមបាតុកររោងចក្រកាត់ដេរ ដែលបង្កឲ្យមានមនុស្សយ៉ាងតិច៤នាក់ ក្នុងចំនោមបាតុករទាំងអស់បានស្លាប់បាត់បង់ជីវិត ការបាត់ខ្លួនយុវជនម្នាក់ អាយុ១៦ឆ្នាំ ហើយមានមនុស្សជាច្រើនទៀតរងរបួស។[41] បន្ទាប់ពីព្រឹត្តិការណ៍នោះមក នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៤ សាលាក្រុងភ្នំពេញបានបិទទីលានប្រជាធិបតេយ្យនៅរាជធានីភ្នំពេញ ហើយក្រសួងការពារជាតិក៏បានប្រកាសផ្អាកការជួបប្រជុំបាតុកម្ម និងការដើរហែរក្បួនរហូតដល់ "សន្តិសុខ និងសុវត្ថិភាពសាធារណៈមានភាពប្រក្រតីវិញ" នៅ

---

[39] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ម.ស.ម.ក "កំណត់ត្រាសង្ខេបស្តីពីកម្ពុជា ៖ សេរីភាពខាងការជួបជុំ "ត្រូវបានព្យួរ"" (ខែមេសា ឆ្នាំ ២០១៤) http://bit.ly/1su1NYS

[40] ម.ស.ម.ក កំណត់ត្រាសង្ខេប ៖ ការប្រើកម្លាំងហួសហេតុទៅលើបាតុករ ក្នុងឆ្នាំ២០១៣ នៅកម្ពុជា (ថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤) http://bit.ly/1tMZWBO ។ ម.ស.ម.ក សេចក្តីថ្លែងការណ៍ ៖ ម.ស.ម.ក ថ្កោលទោសចំពោះការប្រើគ្រាប់រំសេវគ្រោះថ្នាក់ដល់អាយុជីវិតដោយកងកម្លាំងសន្តិសុខស្របពេលដែលការតវ៉ានៅរោងចក្រ អេស អិល កើតមានអំពើហិង្សា (ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣) http://bit.ly/1mVPeUT។ ម.ស.ម.ក សេចក្តីប្រកាសព័ត៌មានបន្ទាន់៖ ការបង្ក្រាបដ៏ធ្ងន់ធ្ងរលើការជួបប្រជុំដោយសន្តិវិធីនៅបរិវេណវត្តភ្នំ ដែលមានអ្នករងរបួស៥នាក់ (ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៣) http://bit.ly/1nGUoUK.

[41] ម.ស.ម.ក សេចក្តីថ្លែងការណ៍ ៖.ម.ស.ម.ក ថ្កោលទោសចំពោះការបង្ក្រាបដោយហិង្សារបស់រដ្ឋាភិបាលលើបញ្ហាសិទ្ធិមនុស្ស និងការធ្វើឲ្យអន់ថយដល់ស្ថានភាពប្រជាធិបតេយ្យនៅកម្ពុជា (ថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤) http://bit.ly/1tFFgNa។ ម.ស.ម.ក សេចក្តីថ្លែងការណ៍ ៖ ម.ស.ម.ក អំពាវនាវឲ្យបញ្ឈប់ការហាមឃាត់ការជួបជុំជាបន្ទាន់ និងបញ្ឈប់ការចាប់ខ្លួនសកម្មជនសិទ្ធិមនុស្ស http://bit.ly/1te5V4W

ទូទាំងប្រទេស។[42] កងកម្លាំងសន្តិសុខ ត្រូវបានដាក់ពង្រាយពេញរាជធានីភ្នំពេញ ដែលជាការរៀបចំរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីបំបាក់ស្មារតីសំឡេងប្រឆាំង។

ក្នុងបរិបទនោះ ករណីចាប់ខ្លួនអ្នកតវ៉ាចំនួន "២៣នាក់" បានក្លាយទៅជារូបភាពនៃការរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិខាងការជួបប្រជុំដោយសន្តិវិធី។

ដោះលែង អ្នកទាំង "២៣នាក់"[43]

នៅថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ ប្រជាពលរដ្ឋ ១០ នាក់ និង ព្រះសង្ឃ ៥អង្គ ត្រូវបានចាប់ខ្លួនបន្ទាប់ពីមានការធ្វើបាតុកម្មរបស់កម្មករកាត់ដេរនៅរោងចក្រ យ៉ាក ជីង ក្បែរទីក្រុងភ្នំពេញ ។ ព្រះសង្ឃត្រូវបានដោះលែងនៅក្នុងថ្ងៃដដែលនោះ។ ក្នុងចំណោមអ្នកទាំងនោះរួមមានប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ លោក វ៉ន ពៅ និងលោក ថេង សាវឿន ស្ថាបនិកសម្ព័ន្ធសហគមន៍កសិករកម្ពុជា និងលោក សម្បត្តិ ពិសិដ្ឋ សមាជិកនៃមជ្ឈមណ្ឌលសិទ្ធិកម្មករកម្ពុជា និងសកម្មជនដីធ្លីដ៏ល្បី ចាន់ ពុទ្ធិសត្ត។ ពួកគេទាំងនោះត្រូវបានវាយដំ និងចាប់ខ្លួនដោយកងទ័ពឆ័ត្រយោងពិសេសលេខ ៩១១ ក្នុងពេលមានការតវ៉ាទាមទារដំឡើងប្រាក់ខែអប្បបរិមា។ ថ្ងៃបន្ទាប់គឺថ្ងៃទី ៣ ខែមករា ឆ្នាំ២០១៤ មនុស្ស ១៣ នាក់ ផ្សេងទៀតត្រូវបានចាប់ខ្លួននៅក្បែរសួនឧស្សាហកម្មកាណាឌី នៅផ្លូវវ៉ៃងស្រែង។

ពួកគេទាំងនោះត្រូវបានចោទប្រកាន់ដំបូងដោយយោងតាមមាត្រា ៤១១ *"ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស"* និងមាត្រា ២១៨ *"ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស"* នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលប្រឈមនឹងការផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០ ដុល្លារ ដល់ ២.៥០០ដុល្លារសហរដ្ឋអាមេរិក។ បុគ្គលទាំង ២៣នាក់ ដែលបានចាប់ខ្លួនត្រូវបានហាមឃាត់មិនឲ្យមានទំនាក់ទំនងជាមួយក្រុមគ្រួសារអស់រយៈពេល ៥ថ្ងៃ គឺរហូតដល់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៤ ដែលនេះជាការរំលោភលើច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ លើសពីនេះទៅទៀត មេធាវីរបស់អ្នកដែលត្រូវបានចាប់ខ្លួនទាំង១០នាក់នោះពុំបានទទួលដំណឹងពិតប្រាកដថាអ្នកទាំងនោះត្រូវបានបញ្ជូនទៅមណ្ឌលឃុំខ្លួនមួយណាទេ ដោយមេធាវីទទួលដំណឹងថា ពួកគេត្រូវបានបញ្ជូនទៅមណ្ឌលកែប្រែ ម១ ប៉ុន្តែការពិតពួកគេត្រូវបញ្ជូនទៅមណ្ឌលកែប្រែ ម៣ ទៅវិញដែលមានទីតាំងនៅតំបន់ដាច់ស្រយាលក្នុងខេត្តកំពង់ចាម។

នៅក្នុងពេលសវនាការ ជនជាប់ចោទ១៩នាក់ ក្នុងចំណោម២៣នាក់ ត្រូវបានចោទប្រកាន់តាមមាត្រា២១៨ ពីបទ *"ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស"* និងមាត្រា៤១១ ពីបទ*"ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស"* នៃក្រមព្រហ្មទណ្ឌ។ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ជនជាប់ចោទ ៤នាក់ រួមមាន វ៉ន ពៅ ចាន់ ពុទ្ធិសត្ត ថេង សាវឿន និង សម្បត្តិ ពិសិដ្ឋ ត្រូវបានប្តូរបទ

[42] ម.ស.ម.ក បញ្ឈប់ការហាមឃាត់ការជួបប្រជុំ (ទំព័រ៤៥)

[43] គម្រោងអ្នកការពារសិទ្ធិមនុស្សផ្តល់ជំនួយដល់អ្នកទាំង ៦នាក់ ក្នុងចំណោម ២៣នាក់ រួមទាំង លោក វ៉ន ពៅ ។

ចោទទៅជា "*ញុះញង់ឲ្យប្រព្រឹត្តអំពើហិង្សា*" និង "*ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ*" តាមមាត្រា ៤៩៤ នៃក្រមព្រហ្មទណ្ឌ។ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋាន ព្រះរាជអាជ្ញាបានលើកឡើងនូវបទចោទ "*ផ្តើមគំនិតប្រព្រឹត្តអំពើហិង្សា*" តាមមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌ។ ចុងបញ្ចប់ ជនជាប់ចោទទាំង ៤ត្រូវបានរកឃើញថាមានទោសធ្ងន់ធ្ងរពីបទផ្តើមគំនិត។

បុគ្គលិក ម.ស.ម.ក បានឃ្លាំមើលសវនាការនៅសាលាដំបូងរាជធានីភ្នំពេញកាលពីខែឧសភា។ សវនាការនោះបានបង្ហាញយ៉ាងច្បាស់ពីកង្វះខាតភស្តុតាងដាក់បន្ទុក ៖ នៅក្នុងបន្ទប់សវនាការទាំងពីរ ឯកសារវីដីអូនៃព្រឹត្តិការណ៍ដែលកើតឡើងនៅខាងមុខរោងចក្រ យ៉ាក ជីង និងនៅលើផ្លូវវែងស្រែងកាលពីថ្ងៃទី២ និងទី៣ ខែមករា មិនបានបង្ហាញពីវត្តមានរបស់ជនជាប់ចោទទាំងអស់នោះឡើយ។ សំណួរជាច្រើនដែលបានចោទសួរទៅជនជាប់ចោទ ដោយចំៗថា តើជនជាប់ចោទមានវត្តមាននៅកន្លែងតវ៉ាដែរឬទេ ហើយការផ្តល់សិក្ខីកម្មរបស់ជនជាប់ចោទមានភាពមិនសមស្របគ្នាដែរឬយ៉ាងណា ហើយថែមទាំងបានព្រងើយកន្តើយចំពោះភស្តុតាងដែលបង្ហាញថា ចម្លើយសារភាពរបស់ពួកគេដំបូងគឺធ្វើឡើងដោយបង្ខិតបង្ខំ។ លើសពីនេះទៅទៀត នៅក្នុងបន្ទប់សវនាការមួយ មេធាវីការពារក្តីបានបង្ហាញវីដេអូមួយដែលគេអាចឮសំឡេងលោក វ៉ន ពៅ ស្រែកមិនឲ្យប្រើហិង្សា។ ចៅក្រម ហាក់ដូចជាបានសន្មតទុកជាមុនអំពីទោសរបស់ជនជាប់ចោទ ដែលផ្ទុយនឹងសិទ្ធិត្រូវបានសន្មតទុកជាមុនថាគ្មានទោស។ ឧទាហរណ៍ ការសាកសួរដោយព្រះរាជអាជ្ញា និងចៅក្រមម្តងហើយម្តងទៀតអំពីវត្តមានរបស់អ្នកទាំងនោះនៅកន្លែងតវ៉ាដែលចង់សំដៅថាពួកគេមានទោស។ លើសពីនេះទៅទៀត ចៅក្រម និងព្រះរាជអាជ្ញាបានហៅអ្នកតវ៉ាទាំងនោះថាជា "ក្រុមខុសច្បាប់" និង "ជនអនាធិបតេយ្យ" ដែលបង្ហាញពីការវិនិច្ឆ័យជាមុនប្រឆាំងនឹងជនជាប់ចោទ។ ចុងក្រោយ ជនជាប់ចោទ២១នាក់ ក្នុងចំណោម ២៣ នាក់ ស្លៀកឯកសណ្ឋានពន្ធនាគារព័ណ៌ទឹកក្រូចដែលមានអក្សរ "ពិរុទ្ធជន" នៅខាងខ្នងដែលនេះបញ្ជាក់ថា ជនជាប់ចោទត្រូវបានផ្តន្ទាទោសរួចហើយ។

សវនាការនេះក៏មានភាពលម្អៀងជាខ្លាំងផងដែរ ដោយសារចៅក្រមអនុញ្ញាតឲ្យបង្ហាញសក្ខីកម្ម និងភស្តុតាងពីភាគីតែម្ខាងនៅក្នុងព្រឹត្តិការណ៍នោះ។ ក្នុងពេលសវនាការ ចៅក្រម និងព្រះរាជអាជ្ញា តែងតែរំខានដល់មេធាវីការពារក្តី និងជនជាប់ចោទនៅពេលពួកគេព្យាយាមលើកឡើងពីអំពើឃោឃៅរបស់កងយោធា និងទាហាន ដើម្បីបង្ហាញភស្តុតាងនៃអំពើហិង្សារបស់កងកម្លាំងសន្តិសុខ។ មេធាវីការពារក្តីត្រូវបានរារាំងក្នុងការបង្ហាញភស្តុតាងមួយចំនួនដូចជា ខ្សែវីដេអូចំនួនពីរ ដែលផ្ទុយទៅវិញ ករណីមនុស្ស១០នាក់ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០១៤ ទាំងចៅក្រម និងព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងថ្មីក្នុងកំឡុងពេលសវនាការ ដែលមិនពាក់ព័ន្ធនឹងឯកសារក្នុងសំណុំរឿង។ ជាចុងក្រោយ សវនាការបានប្រព្រឹត្តទៅដោយស្ទើរតែពុំមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ប៉ុន្តែសេចក្តីថ្លែងការណ៍របស់ពួកគេត្រូវបានអានយ៉ាងឮៗនៅក្នុងបន្ទប់សវនាការ ព្រមទាំងការពារមិន

ឲ្យមានការសាកសួរពីសំណាក់មេធាវីការពារក្តីនោះទេ។[44]

សវនាការរយៈពេល ៥ថ្ងៃ លើករណីជនជាប់ចោទ១០នាក់ ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី២ ខែមករា បានបង្ហាញពីបញ្ហាសុខភាពទាំងផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងររបស់ជនជាប់ចោទមួយចំនួនដែលត្រូវបានតុលាការបដិសេធសំណើសុំនៅក្រៅឃុំបណ្តោះអាសន្នជាច្រើនលើកច្រើនសារ។ អំឡុងពេលសវនាការ សម្បត្តិ ពិសិដ្ឋ បានលើកឡើងពីបញ្ហាដៃរបស់គាត់ដែលបាក់ក្នុងពេលគាត់រងការវាយបង្ក្រាបពីសំណាក់ទាហាន និងការពិបាកដកដង្ហើម។ លោក វ៉ន់ ពៅ ក៏បានលើកឡើងពីបញ្ហាសុខភាពរបស់គាត់រាល់ពេលដែលបុគ្គលិក ម.ស.ម.កបានទៅសួរសុខទុក្ខក្នុងពេលជាប់ឃុំ និងបានដួលសន្លប់នៅក្នុងបន្ទប់សវនាការ គឺបានបង្ហាញអំពីបញ្ហាផ្លូវកាយ និងផ្លូវចិត្តដែលបណ្តាលមកពីអំពើហិង្សារបស់កងកម្លាំងសន្តិសុខ គួបផ្សំជាមួយនឹងសម្ពាធនៃការជាប់ឃុំឃាំង។

សាលក្រមត្រូវបានប្រកាសកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ អ្នកការពារសិទ្ធិមនុស្ស ដូចជា លោក វ៉ន់ ពៅ សម្បត្តិ ពិសិទ្ធិ ចាន់ ពុទ្ធិស័ក្តិ ត្រូវបានតុលាការកាត់ទោសជាប់ពន្ធនាគាររយៈពេល ៤ឆ្នាំ និង ៦ខែ ខណៈដែល ថេង សាវឿន ត្រូវបានកាត់ទោសជាប់ពន្ធនាគាររយៈពេល ៤ឆ្នាំ។ មនុស្ស ៦នាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួននៅមុខរោងចក្រ យ៉ាក ជីង កាលពីថ្ងៃទី២ ខែមករា ឆ្នាំ ២០១៤ ត្រូវបានកាត់ទោសជាប់ពន្ធនាគារពីរយៈពេលចាប់ពី ២ឆ្នាំ និង ៦ខែ និងដល់ ៣ឆ្នាំ។ ចំណែកមនុស្ស១៣នាក់ ដែលត្រូវបានចាប់ខ្លួននៅលើផ្លូវរវែងស្រែងកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៤ ត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារពី ១ឆ្នាំ ទៅ ៤ឆ្នាំ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារសកម្មភាពខ្លាំងក្លាពីសង្គមស៊ីវិល និងសហគមន៍អន្តរជាតិ ទោសអ្នកទាំងអស់នោះត្រូវបានព្យួរ ហើយពួកគេត្រូវបានដោះលែងនៅថ្ងៃនោះដែរ។ ថ្វីបើជនជាប់ទោសទាំង ២៣នាក់ ត្រូវបានព្យួរទោស និងដោះលែងក៏ពួកគេនៅតែមានទោសតាមរយៈសាលក្រមដែល។ ពួកគេបានសម្រេចចិត្តប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទោស ដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់ខ្លួន ក៏ប៉ុន្តែរហូតមកដល់ខែមករា ឆ្នាំ២០១៥ សាលាឧទ្ធរណ៍នៅមិនទាន់បានទទួលសំណុំរឿងពីសាលាដំបូងរាជធានីភ្នំពេញនៅឡើយ។

តាមរយៈនីតិវិធីនេះបានបង្ហាញឲ្យឃើញថា សាលក្រមដែលបញ្ជាក់ពីទោសទាំងនោះ គឺយោងទៅលើការសម្រេចបែបនយោបាយច្រើនជាងកស្តុតាង។ បន្ថែមពីនេះទៅទៀត ក៏បានបង្ហាញពីកង្វះឯករាជ្យភាពរបស់តុលាការកម្ពុជា ដែលនឹងត្រូវរងការគំរាមកំហែងបន្ថែមទៀតតាមរយៈច្បាប់ចំនួនបី

[44] ម.ស.ម.ក "សេចក្តីថ្លែងការណ៍ ៖ ម.ស.ម.ក អំពាវនាវឲ្យមានការលើកលែងបទចោទប្រកាន់ និងដោះលែងអ្នកទាំង២៣នាក់ជាបន្ទាន់" http://bit.ly/1pK2hgG.

ពាក់ព័ន្ធនឹងតុលាការដែលត្រូវបានអនុម័តកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ។[45] ការចាប់ខ្លួន និងផ្តន្ទាទោសនេះ ជាសញ្ញាបញ្ជាក់ពីរបត់នៃការគាបសង្កត់អ្នកការពារសិទ្ធិមនុស្សរបស់រដ្ឋាភិបាល។[46]

ខណៈពេលការហាមឃាត់ការប្រមូលផ្តុំ ការធ្វើបាតុកម្ម និងការហែក្បួនដោយសេចក្តីប្រកាសធ្វើឡើងនៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៤ ត្រូវបានប្រើប្រាស់ជាឧបករណ៍ដើម្បីដាក់សម្ពាធក្រុមអ្នកតវ៉ាដោយសន្តិវិធីដែលបានបន្តសកម្មភាពរបស់ពួកគេ។

កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ការហាមប្រាមក្នុងការជួបប្រជុំគ្នាហាក់ដូចជាត្រូវបានលុបចោលពីសំណាក់ដោយនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងសុន្ទរកថាមួយនៅខេត្តព្រះសីហនុ ថា "*ឥឡូវនេះខ្ញុំមិនស្នើឲ្យមានការធ្វើបាតុកម្មនោះទេ ប៉ុន្តែខ្ញុំក៏នឹងមិនហាមឃាត់ដែរ* " លោកបានបន្ថែមទៀតថាលោក "*ត្រូវតែជានានូវសន្តិភាពសម្រាប់ទាំងអស់គ្នា ក៏ដូចជានានូវសិទ្ធិក្នុងការប្រមូលផ្តុំសម្រាប់ទាំងអស់គ្នា*"។ សេចក្តីប្រកាសនេះបាននាំឲ្យមានការភាន់ច្រឡំជាច្រើនក្នុងចំណោមមន្ត្រីរដ្ឋាភិបាល ថាតើការហាមឃាត់នោះត្រូវបានលុបចោលឬក៏យ៉ាងណានោះ។ ទោះជាយ៉ាងណា ការតវ៉ាផ្សេងទៀតត្រូវបានហាមឃាត់ ដែលបង្ហាញថា នៅក្នុងការអនុវត្តជាក់ស្តែងការហាមប្រាមនៅតែបន្ត។ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ បន្ទាប់ពីសុន្ទរកថារបស់លោក ហ៊ុន សែន អាជ្ញាធរបានប្រកាសថា ទីលានប្រជាធិបតេយ្យនៅតែត្រូវបិទដោយគ្មានពេលកំណត់។ ជាលទ្ធផល សាលារាជធានីភ្នំពេញបានច្រានចោលសំណើរបស់សហជីព និងសមាគមនានាជាបន្តបន្ទាប់ស្តីពីការរៀបចំការជួបប្រជុំជាសាធារណៈនៅទីលានប្រជាធិបតេយ្យ។

ចំនុចពិសេសពីរយ៉ាងបន្ថែមទៀតដែលបង្ហាញពីចរិតលក្ខណៈនៃការគាបសង្កត់នេះ ៖

- ការប្រើប្រាស់វិធីចាប់ខ្លួនតាមអំពើចិត្ត និងការឃុំឃាំងបណ្តោះអាសន្នប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស និងអ្នកតវ៉ា
- ការតម្រូវឲ្យពួកគេចុះហត្ថលេខាលើកិច្ចសន្យាមិនចូលរួមនៅក្នុងការតវ៉ានាពេលអនាគត ដែលជាថ្នូរនឹងការដោះលែង ឬចៀសវាងការចោទប្រកាន់។

កាលពីប៉ុន្មានឆ្នាំមុន រដ្ឋាភិបាលបានតម្រូវឲ្យអ្នកការពារសិទ្ធិមនុស្សចុះហត្ថលេខាឈប់តវ៉ានាពេលអនាគត។ វិធីសាស្ត្រស្រដៀងគ្នានេះដែរ ក៏ត្រូវបានយកមកប្រើកាលពីថ្ងៃទី២១ ខែមេសា ឆ្នាំ

[45] កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ "ច្បាប់បីពាក់ព័ន្ធនឹងតុលាការ" ដែលបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ នរោត្តម សីហមុន្នី។ សូមមើល Stuart White, 'King OKs Judiciary Laws' (15 2014), http://goo.gl/fOsa75.

[46] ម.ស.ម.ក សេចក្តីថ្លែងការណ៍ ៖ ម.ស.ម.ក សូមស្វាគមន៍ចំពោះការដោះអ្នកតវ៉ាទាំង២៥នាក់ ប៉ុន្តែសូមថ្កោលទោសយ៉ាងខ្លាំងចំពោះការផ្តន្ទាទោសទៅលើពួកគេ (ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤) http://bit.ly/1AbKHEO

២០១១ ជាមួយនឹងសមាជិកសហគមន៍បឹងកក់ និងកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ ជាមួយនឹងសមាជិកសហជីពលោក រ៉ុង បញ្ញា។[47] ក្នុងឆ្នាំ ២០១៤ ការអនុវត្តនេះបានកើនឡើង។ វិធីសាស្ត្រនេះត្រូវបានប្រើជាញឹកញាប់ក្នុងអំឡុងពេលប្រាំខែដំបូងក្នុងឆ្នាំ២០១៤ ខណៈពេលដែលការតវ៉ា និងបាតុកម្មត្រូវបានធ្វើឡើងជាញឹកញាប់។ ម.ស.ម.ក បានចងក្រងជាឯកសារក្នុងអំឡុងពេលនោះមានចំនួន ៥ ករណី ជាមួយនឹងមនុស្សសរុបចំនួន ៣២នាក់។

ការអនុវត្តបែបនេះបង្ហាញពីការគម្រាមកំហែងចាប់ខ្លួនសកម្មជនសិទ្ធិមនុស្ស និងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើការងាររបស់ អ.ក.ស.ម ដោយសារជាការរឹតត្បិតការអនុវត្តសិទ្ធិសេរីភាពខាងការជួបប្រជុំ។ មាត្រា ៥ នៃសេចក្តីប្រកាសជាសកលស្តីពី អ.ក.ស.ម របស់អង្គការសហប្រជាជាតិ[48] ទទួលស្គាល់សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី ហើយអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សចាត់ទុកថា សិទ្ធិក្នុងការជួបប្រជុំដោយសន្តិវិធី គឺសំខាន់សម្រាប់អ្នកការពារសិទ្ធិមនុស្សដែលបំពេញការងារនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងអន្តរជាតិដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស។ បើគ្មានការអនុវត្តសិទ្ធិនេះទេ អ្នកការពារសិទ្ធិមនុស្សនឹងត្រូវបានរឹតត្បិតក្នុងការបំពេញតួនាទីជាមូលដ្ឋានរបស់ខ្លួនក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។[49]

ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានសម្គាល់ថា *"វាជារឿងធម្មតាដែលអាជ្ញាធរជារឿយៗប្រើនបរាជ័យក្នុងការជំរុញអ្នកការពារសិទ្ធិមនុស្ស នៅក្រោមការគ្រប់គ្រង"ភាពខុសច្បាប់" និងប្រើប្រាស់ករណីនេះជាមូលដ្ឋានក្នុងការចាប់ខ្លួនជាប្រចាំ ការឃុំខ្លួន និងការផ្តន្ទាទោសជាបន្តបន្ទាប់"*។ [50] ការគម្រាមកំហែងក្នុងការចាប់ខ្លួន គឺផ្ទុយនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សក្នុងការការពារសិទ្ធិមនុស្សនៅក្នុងបរិបទសិទ្ធិក្នុងការតវ៉ាដែលចែងថា ៖ *"មនុស្សគ្រប់រូបត្រូវតែអាចបញ្ចេញទុក្ខសោក ឬបំណងប្រាថ្នារបស់ខ្លួនដោយសន្តិវិធី តាមរយៈការតវ៉ាជាសាធារណៈ ដោយគ្មានការភ័យខ្លាចថានឹងត្រូវរងរបួស ការវាយដំ ការចាប់ខ្លួនតាមអំពើចិត្ត និងឃុំខ្លួន ការធ្វើទារុណកម្ម ការសម្លាប់ ឬការបាត់ខ្លួនដោយបង្ខំ"*។[51] លើសពីនេះទៅទៀត រាល់ការចាប់ខ្លួនទាំងឡាយ

---

[47] ដូចខាងលើ

[48] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៥៣/១៤៤ សេចក្តីប្រកាសស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ក្រុម និងសរីរាង្គសង្គម ដើម្បីលើកកម្ពស់ និងការពារ និងទទួលស្គាល់ជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន (ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៩៨) http://bit.ly/1fbj99p.

[49] មហាសន្និបាតអង្គការសហប្រជាជាតិ រាយការណ៍ដោយអ្នកតំណាងពិសេសរបស់អគ្គលេខាធិការសិទ្ធិមនុស្សអំពីអ្នកការពារសិទ្ធិមនុស្ស ឯកសារអង្គការសហប្រជាជាតិ A/61/312 (ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៦) កថាខ័ណ្ឌ៧៦ និងសេចក្តីណែនាំ http://bit.ly/1fbiAN0.

[50] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស "អ្នកការពារសិទ្ធិមនុស្ស ៖ ការពារសិទ្ធិក្នុងការការពារសិទ្ធិមនុស្ស" (សលាកបត្រព័ត៌មានលេខ ២៩) http://bit.ly/1iFTNUY.

[51] សេចក្តីប្រកាសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស "ការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅក្នុងបរិបទតវ៉ាដោយសន្តិវិធី" A / HRC / RES / ១៩/៣៥ (ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២) http://bit.ly/1llo3qn.

ណានាពេលខាងមុខដែលសំអាងតែទៅលើកិច្ចសន្យាដែលចុះហត្ថលេខារួចមកហើយនោះ អាចចាត់ទុកថាជាការឃុំឃាំងតាមអំពើចិត្ត និងខុសច្បាប់។[52]

ជាងនេះទៅទៀតការចុះហត្ថលេខាលើកិច្ចសន្យា មិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃសមាមាត្រ និងភាពស្របច្បាប់ដែលចាំបាច់ដើម្បីបង្ហាញអំពីភាពត្រឹមត្រូវក្នុងការរឹតត្បិតសិទ្ធិសេរីភាពខាងការជួបប្រជុំគ្នានោះទេ។ កិច្ចសន្យាបានហាមប្រាមអ្នកការពារសិទ្ធិមនុស្សក្នុងការតវ៉ាផ្សេងទៀត និងធ្វើឲ្យកាន់តែមានការរឹតត្បិតទៅលើសិទ្ធិសេរីភាពខាងការជួបប្រជុំ។ ជាងនេះទៅទៀត ឯកសារទាំងនេះពុំមានមូលដ្ឋានច្បាប់នោះទេ ដោយសារការចុះហត្ថលេខាបានមកពីការគម្រាមកំហែង និងការដាក់សម្ពាធ ដែលជាញឹកញាប់ធ្វើឡើងនៅប៉ុស្តិ៍នគបាល ខណៈពេលអ្នកការពារសិទ្ធិមនុស្សកំពុងត្រូវបានឃុំខ្លួន ឯកសារទាំងនោះត្រូវទុកជាមោឃៈ និងគ្មានសុពលភាព ហើយមិនអាចត្រូវបានចាត់ទុកថា ជា "កិច្ចសន្យា" រវាងអាជ្ញាធរ និងរូបវន្តបុគ្គលបានឡើយ ។ ដូច្នេះពួកគេពុំជាប់កាតព្វកិច្ចផ្លូវច្បាប់ឡើយ។

ការឃុំខ្លួនបណ្តោះអាសន្ន និងការប្រើប្រាស់មធ្យោបាយដោះលែងដោយមានលក្ខខណ្ឌមិនត្រឹមត្រូវ

នៅថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១៤ សកម្មជនដីធ្លី ៥នាក់ (អ្នកស្រី ទេព វន្នី បូ ធវី សុង ស្រីលាក ផាន់ ឈុនរ៉េត និង យ៉ោម បុប្ផា) ត្រូវបានចាប់ខ្លួន ខណៈពេលដែលពួកគេបានដើរហែក្បួនឆ្ពោះទៅស្ថានទូតបារាំង ដើម្បីទាមទារឲ្យមានការដោះលែង លោក វ៉ន ពៅ និងបាតុករអហិង្សា ៩នាក់ផ្សេងទៀត។ អ្នកទាំងនោះត្រូវបានដោះលែង បន្ទាប់ពីមានយល់ព្រមចុះហត្ថលេខា ដោយបញ្ជាក់ថានឹងមិនចូលរួមក្នុងការតវ៉ាផ្សេងទៀតនោះទេ។[53]

ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ នគបាល និងកងកម្លាំងសន្តិសុខបានចាប់ខ្លួនលោក សុខ ឈុនអឿង(អនុប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ "IDEA") ដែលបានព្យាយាមបួងសួងឲ្យមានការដោះលែងអ្នកទាំង ២៣ ដែលបានជាប់ឃុំ ចាប់តាំងពីមានការបង្ក្រាបកាលពីថ្ងៃទី២ និងទី៣ ខែមករា ឆ្នាំ២០១៤ ។ លោក សុខ ឈុនអឿង ត្រូវបានឃាត់ខ្លួនមួយយប់នៅឯស្នងការនគបាលរាជធានីភ្នំពេញ និងត្រូវបានដោះលែងមកវិញប្រហែលជាម៉ោង ១០ព្រឹក នៅថ្ងៃបន្ទាប់ពីគាត់បានចុះហត្ថលេខាយល់ព្រមបញ្ឈប់ការធ្វើសកម្មភាពខុសច្បាប់ទាំងឡាយណា ដែលជាការញុះញង់ឲ្យមានការធ្វើបាតុកម្មខុសច្បាប់ រាយការណ៍រាល់សកម្មភាពខុសច្បាប់ និងសហការណ៍

[52] សូមមើល សេចក្តីព្រាងយោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ៣៥(មាត្រា៩ សេរីភាព និងសុវត្ថិភាពបុគ្គល) (ឆ្នាំ២០១៣) ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C១០៧/R.៣ កថាខណ្ឌទី ១៧ គណៈកម្មាធិការសិទ្ធិមនុស្ស រួមទាំងសង្កេតការណ៍លើករណីប្រទេសកាណាដា (២០០៦) ឯកសាររបស់អង្គការសហប្រជាជាតិ CCPR/C//CAN/CO/៥ កថាខណ្ឌទី ២០ គណៈកម្មាធិការសិទ្ធិមនុស្ស រួមទាំងសង្កេតការណ៍លើករណីប្រទេសម៉ូលដូវ៉ា (២០០៩) ឯកសាររបស់អង្គការសហប្រជាជាតិ កថាខណ្ឌទី៨ http://bit.ly/1fbdi3S.

[53] ម.ស.ម.ក សេចក្តីប្រកាសព័ត៌មានបន្ទាន់ ៖ ការចាប់ខ្លួនបណ្តោះអាសន្នលើសកម្មជនដីធ្លី និងការហាមប្រាមមិនឲ្យធ្វើបាតុកម្ម (ថ្ងៃទី ១ ខែមិថុនា ឆ្នាំ២០១៤) http://bit.ly/1oqyuo0.

ជាមួយរដ្ឋាភិបាល។[54]

នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ កងកម្លាំងសន្តិសុខបានចាប់ខ្លួនអ្នកការពារសិទ្ធិមនុស្ស ១១នាក់ និងយកទៅឃុំឃាំងនៅស្នងការនគរបាលរាជធានីភ្នំពេញអស់រយៈពេលជាច្រើនម៉ោង។ មនុស្សទាំង ១១នាក់បានព្យាយាមយកញត្តិទៅដាក់នៅតាមស្ថានទូតមួយចំនួនរួមមានស្ថានទូតអាមេរិក និងបារាំង ដើម្បីអំពាវនាវឲ្យមានការដោះលែងអ្នកតវ៉ាទាំង ២៣នាក់ ដែលត្រូវបានអាជ្ញាធរឃុំខ្លួនក្នុងពេលបង្ក្រាបកូដកម្មរបស់កម្មកររោងចក្រកាត់ដេរកាលពីថ្ងៃទី២ និងទី៣។ ក្នុងចំណោមអ្នកទាំងនោះរួមមាអ្នកស្រី ទេព វន្នី សុង ស្រីលាភ យ៉ោម បុប្ផា ផាន់ ឈុនរ៉ែត ភួង សុភាព អ៊ឹម ស្រីទូច ប៉ូវ សោភា និង ងួន គីមឡាង ដែលជាសកម្មជនមកពីតំបន់បឹងកក់ លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ អ្នកស្រី ឈាង ធីតា សមាជិកសហភាពសម្ព័ន្ធពាណិជ្ជកម្មកម្ពុជា និង កញ្ញា ឡុង គឹមហៀង មន្ត្រីទំនាក់ទំនងនៃក្រុមការងារពិសេសសិទ្ធិលំនៅឋាន។ ការចាប់ខ្លួនធ្វើឡើងកំឡុងពេលធ្វើបាតុកម្មដែលចាប់ផ្តើមនៅមុខស្ថានទូតអាមេរិក ដើម្បីដាក់ញត្តិអំពាវនាវឲ្យមានការដោះលែងអ្នកទាំង ២៣ ដែលនៅជាប់ឃុំក្នុងពន្ធនាគារ បន្ទាប់ពីការបង្ក្រាបដោយហិង្សាលើបាតុកម្មរបស់កម្មកររោងចក្រកាត់ដេរកាលពីដើមខែ។ អ្នកទាំង១១ ត្រូវបានគេដោះលែងវិញ នៅក្នុងថ្ងៃដដែល បន្ទាប់ពីពួកគេបានចុះហត្ថលេខាបញ្ជាក់ថា នឹងឈប់ចូលរួម ដឹកនាំ ឬក៏ញុះញង់សកម្មភាពខុសច្បាប់ ឬតវ៉ានាពេលខាងមុខទៀត។[55]

ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៤ យុវជន ៧នាក់ ត្រូវបានឃាត់ខ្លួនបណ្តោះអាសន្នដោយសារពួកគេដើរហែក្បួនតវ៉ាស្វែងរកសន្តិភាព។ យុវជនទាំងនោះគឺជាសមាជិកនៃអង្គការ ក្លឹបយុវជនខ្មែរមហានគរ[56] ដែលធ្វើការលើកកម្ពស់ ការតស៊ូមតិរបស់យុវជន និងយុត្តិធម៌សង្គម។ ថ្ងៃដដែលនោះ ពួកគេត្រូវបានដោះលែងមកវិញបន្ទាប់ពីមានសរសេរកិច្ចសន្យាថា ឈប់ដើរហែក្បួនដោយគ្មានការអនុញ្ញាត។

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ មេដឹកនាំ និងសមាជិកនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(CCAWDU) ចំនួន ៨រូប ត្រូវបានចាប់ខ្លួននៅស្រុកបាទី ខេត្តតាកែវ ខណៈពេលមានការធ្វើកូដកម្មរបស់កម្មករនៅរោងចក្រ ចេ អេស ឌី JSD Textile Co. Ltd។ ក្រុមកូដករបានធ្វើការតវ៉ាទាមទារឲ្យមានលក្ខខណ្ឌការងារប្រសើរឡើង។ អ្នកទាំង ៨នាក់នោះត្រូវបានឃុំខ្លួនរយៈពេល ៤៨ម៉ោង និងសាកសួរពាក់ព័ន្ធនឹងករណីចោទប្រកាន់ពីបទផ្តើមគំនិតប្រព្រឹត្តបទឧក្រិដ្ឋ គំរាមកំផ្លិចបំផ្លាញ មិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការ និងជាអ្នកផ្តើមគំនិត។ ថ្ងៃទី២៥ ខែឧសភា ពួក

[54] ម.ស.ម.ក "អ្នកការពារសិទ្ធិមនុស្ស/សេរីភាពបញ្ចេញមតិ សេចក្តីប្រកាសព័ត៌មានបន្ទាន់ បច្ចុប្បន្នភាព ៖ ការបន្តការចាប់ខ្លួនបណ្តោះអាសន្ននៃសកម្មជនសិទ្ធិមនុស្ស និងការហាមប្រាមការធ្វើបាតុកម្ម" (ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤) http://bit.ly/1pnRWIh.

[55] ដូចខាងលើ

[56] ហ៊ុល រស្មី និង មុំច ដាវ៉ា "ព្រឹត្តិការណ៍ការលើកកម្ពស់សន្តិភាពត្រូវបានបញ្ឈប់ដោយអាជ្ញាធរ" *ខេមបូឌា ដេលី* (ភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤) http://bit.ly/1rrjafZ.

គេត្រូវបានដោះលែងក្រៅឃុំបន្ទាប់ពីប្រធានសហជីពបានចុះហត្ថលេខាធានាថា អ្នកទាំង៨នឹងមិនបង្ក បញ្ហាដល់រោងចក្រ ហើយពួកគេនឹងបង្ហាញខ្លួននៅពេលដែលមានការកោះហៅពីព្រះរាជអាជ្ញា។ [57] ពួកគេបន្តស្ថិតក្រោមការចោទប្រកាន់(តាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដោយសារអនុវត្តសិទ្ធិធ្វើកូដកម្ម។

ការយាយីតាមផ្លូវតុលាការ ៖ ឧបករណ៍ដែលត្រូវបានប្រើប្រាស់ជាទូទៅ ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស

ការយាយីតាមផ្លូវតុលាការរួមមានការចោទប្រកាន់មិនត្រឹមត្រូវពីបទព្រហ្មទណ្ឌ និងការរំលោភបំពានដោយឃុំខ្លួនបណ្តោះអាសន្នបានក្លាយទៅជាយុទ្ធសាស្ត្រជាប្រព័ន្ធ ប្រើប្រាស់ដើម្បីរារាំងអ្នកការពារសិទ្ធិមនុស្សពីការបំពេញការងាររបស់ខ្លួន។ ក្នុងឆ្នាំ២០១៤ ជនរងគ្រោះ ៩១ ភាគរយដែលទទួលបានការគាំទ្រពី ម.ស.ម.ក គឺប្រឈមនឹងការយាយីតាមផ្លូវតុលាការ។

ការយាយីតាមផ្លូវតុលាការកើតឡើងនៅពេលដែលស្ថាប័ននីតិប្រតិបត្តិ និងឧកញ៉ាដែលមានអំណាចអាចប្រើឥទ្ធិពលលើនគរបាល និងតុលាការដើម្បីបម្រើផលប្រយោជន៍របស់ខ្លួន និងដើម្បីរារាំងអ្នកការពារសិទ្ធិមនុស្សពីការអនុវត្តន៍ការងារការពារសិទ្ធិមនុស្ស។ ការយាយីតាមផ្លូវតុលាការស្តែងឡើងតាមរយៈការកោះហៅឲ្យចូលទៅបំភ្លឺនៅតុលាការ ការចោទប្រកាន់ ឬការផ្តន្ទាទោសជាក់លាក់ដែលពេលខ្លះប្រឈមនឹងការដាក់ទោសយ៉ាងធ្ងន់ធ្ងរ។ ការធ្វើបែបនេះបង្កការលំបាកដល់ការងាររបស់អ្នកការពារសិទ្ធិមនុស្ស ខណៈដែលពួកគេមិនអាចបន្តសកម្មភាព ដោយសារពួកគេជាប់ពន្ធនាគារ ហើយវាក៏រារាំងអ្នកផ្សេងទៀតមិនឲ្យធ្វើសកម្មភាពការពារសិទ្ធិមនុស្សខ្លួនផ្ទាល់ និងសិទ្ធិអ្នកដទៃ។ ការយាយីតាមផ្លូវតុលាការនៅក្នុងប្រទេសកម្ពុជា គឺបណ្តាលមកពីកង្វះខាតការបែងចែកអំណាច និងការបន្តជះឥទ្ធិពលលើប្រព័ន្ធតុលាការរបស់អំណាចនីតិប្រតិបត្តិ។ ស្ថានភាពនេះកើនឡើងកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារអំពើពុករលួយនៅមានកម្រិតខ្ពស់ និងការឃុបឃិតគ្នារវាងអាជ្ញាធរ និងបុគ្គលមានឥទ្ធិពល ឬក្រុមហ៊ុន។

ក្នុងឆ្នាំ២០១៤ ករណីការយាយីតាមផ្លូវតុលាការ បានប៉ះពាល់ដល់សកម្មជនដីធ្លី ២៧ភាគរយនៃករណីសរុបរបស់ ម.ស.ម.ក។ ករណីទាំងនេះគឺមានលក្ខណៈពិសេសមួយចំនួន។ ទីមួយ ការជំរុញឲ្យមានករណីបែបនេះកើតឡើងគឺពាក់ព័ន្ធនឹងជម្លោះរវាងក្រុមហ៊ុន និងអ្នកភូមិដែលមានសិទ្ធិកាន់កាប់លើដីធ្លីនោះ។ ទីពីរ ជនរងគ្រោះភាគច្រើនដែលរងការយាយីតាមផ្លូវតុលាការ គឺអ្នកដែលគៀងគរ និងជាតំណាងសហគមន៍។ ករណីខ្លះទៀត ពួកគេបានទប់ស្កាត់ម៉ាស៊ីនអារឈើ ឬបានរារាំងបុគ្គលិកក្រុមហ៊ុនដែលកំពុងធ្វើការនៅលើដីដែលមានជម្លោះនោះ។ ទីបី ពួកគេជាញឹកញាប់ត្រូវបានចោទប្រកាន់ពីបទញុះញង់ ឬបទធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស។ នៅឆ្នាំ២០១៤ មនុស្ស ១២

[57] ម.ស.ម.ក សេចក្តីប្រកាសព័ត៌មានបន្ទាន់ ៖ ការចោទប្រកាន់ និងការឃុំខ្លួនសមាជិកសហជីពប្រាំបីនាក់(ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១៤) http://bit.ly/1pbxrbH.

នាក់ ដែល ម.ស.ម.ក បានគាំទ្រត្រូវបានចោទប្រកាន់ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃមានស្ថានទម្ងន់ទោស និង ៤នាក់ត្រូវបានចោទប្រកាន់ពីបទប្រើហិង្សាប្រឆាំងនឹងអ្នកកាន់កាប់។ លើសពីនេះទៅទៀត មានមនុស្ស ៦នាក់ទៀតត្រូវបានសាកសួរពាក់ព័ន្ធនឹងបទញុះញង់ឲ្យបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ៤នាក់ទៀតពីបទញុះញង់អ្នកភូមិឲ្យប្រព្រឹត្តអំពើខុសច្បាប់ និង ១០នាក់ផ្សេងទៀត ត្រូវបានសាកសួរពាក់ព័ន្ធនឹងការជ្រៀតជ្រែកកិច្ចការសាធារណៈ។

ការយាយីតាមផ្លូវតុលាការទៅលើអ្នកការពារសិទ្ធិដីធ្លី

លោក លី ស្រ៊ាខេង អាយុ៥៨ឆ្នាំ រស់នៅជាមួយភរិយា និងកូនប្រុសស្រី នៅតំបន់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាកន្លែងដែលពួកគេបានកាន់កាប់តាំងពីការដួលរលំនៃរបប ប៉ុលពត ឆ្នាំ១៩៧៩ ។ លោក លី ស្រ៊ាខេង បានជាប់ពាក់ព័ន្ធនឹងជម្លោះដីធ្លីតាំងពីឆ្នាំ២០០៥ ពេលដែលលោកព្យាយាមចុះបញ្ជីដី យោងតាមច្បាប់ភូមិបាលឆ្នាំ២០០១ ប៉ុន្តែតែងតែមិនបានសម្រេចដោយសារអាជ្ញាធរចោទថា គាត់បានមករស់នៅខុសច្បាប់លើដីសាធារណៈរបស់រដ្ឋ។[58]

ដីដែលក្រុមគ្រួសារលោក លី ស្រ៊ាខេង និងប្រជាពលរដ្ឋផ្សេងទៀតកំពុងរស់នៅ ក៏ត្រូវបានការិយាល័យក្រុមប្រឹក្សាសង្កាត់ និងទីស្នាក់ការរបស់គណបក្សប្រជាជនកម្ពុជាកាន់កាប់មួយផ្នែក។ ក្នុងឆ្នាំ២០០៧ ចៅសង្កាត់នៅទីនោះបានដោះដូរដីជាមួយក្រុមហ៊ុន ឃុន សៀ នាំចេញ នាំចូល របស់លោកឧកញ៉ា ឃុន សៀ ។ កាលពីដំបូងឡើយមានប្រជាជន ៧ គ្រួសារបានជាប់ពាក់ព័ន្ធនឹងជម្លោះ ហើយបានប្រឈមនឹងការគំរាមកំហែង និងបំភ័យ ក្នុងបំណងជាក់សម្តែងឲ្យពួកគេចាកចេញពីដីនោះ។ ចាប់ពីពេលនោះមក ក្រុមគ្រួសារទាំងអស់ លើកលែងតែលោក លី ស្រ៊ាខេង ចាកចេញពីទីតាំងនោះ។[59]

នៅឆ្នាំ២០១០ ទីស្តីការគណៈរដ្ឋមន្ត្រីបានចេញសេចក្តីប្រកាសថា ដីជម្លោះនោះជាដីកម្មសិទ្ធិរបស់រដ្ឋ ដូច្នេះអាចដោះដូរបានដោយស្របច្បាប់ជាមួយក្រុមហ៊ុន ឃុន សៀ។ នៅឆ្នាំ២០១៣ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញប័ណ្ណកម្មសិទ្ធិបញ្ជាក់ថា សាលារាជធានីភ្នំពេញបានលក់ដីនោះឲ្យលោកឧកញ៉ា ឃុន សៀ រួចហើយ។ [60]

ក្រុមគ្រួសារលោក លី ស្រ៊ាខេង បានរងការគំរាមកំហែង ការសម្លុតបំភ័យ និងការវាយប្រហារពីសំណាក់កម្លាំងសន្តិសុខដែលជួលដោយក្រុមហ៊ុន ឃុន សៀ រួមមានទាំងការដុត ការបំពារបំពានលើរូបរាងកាយ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ពួកគេ ហើយនៅខែតុលា ឆ្នាំ២០១៣ មានការបោះ

[58] ម.ស.ម.ក "លី ស្រ៊ាខេង ៖ គ្រួសារដែលប្រឈមនឹងការគម្រាមកំហែង និងវាយដំនៅភ្នំពេញ" http://goo.gl/vHLHT7.

[59] ដូចខាងលើ

[60] ម.ស.ម.ក "ការគំរាមកំហែងប្រឆាំងនឹងអ្នកសម្របសម្រួលគម្រោងកំណែទម្រង់ដីធ្លីរបស់ ម.ស.ម.ក" សេចក្តីប្រកាសព័ត៌មានបន្ទាន់ (ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤) http://goo.gl/g34hF2.

ពស់ពិស ៣ក្បាលចូលក្នុងផ្ទះរបស់លោក ស្រ៊ាខេង ថែមទៀត។ [61] ក្រុមគ្រួសាររលោក លី ស្រ៊ាខេង បានដាក់ពាក្យបណ្តឹងជាច្រើនលើកច្រើនសារទៅសាលាដំបូងរាជធានីភ្នំពេញ ប៉ុន្តែមកដល់ពេលនេះ នៅមិនទាន់មានការការស៊ើបអង្កេតណាមួយធ្វើឡើងនៅឡើយ ហើយជនដៃដល់នៅមិនទាន់រកឃើញនៅឡើយ។[62]

ផ្ទុយទៅវិញ ក្រុមគ្រួសាររលោក លី ស្រ៊ាខេង រងការប្តឹងផ្តល់ជាច្រើនករណីពីក្រុមហ៊ុន ឃុន សៀ ហើយត្រូវបានកោះហៅទៅសាកសួរជាច្រើនលើកច្រើនសារ។ ថ្មីៗកាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅវេលាម៉ោង ១១ និង ៣០នាទី នគរបាលបានចាប់ខ្លួនលោក ខេង នៅឯផ្ទះរបស់គាត់ និងបង្ខំគាត់ឲ្យចូលឡាននគរបាល ដោយពុំមានបង្ហាញដីកា និងទុកពេលឲ្យគាត់បានស្លៀកសម្លៀកបំពាក់សមរម្យនោះទេ។[63] នៅវេលាម៉ោង ៤ រសៀល ថ្ងៃដដែល កូនស្រីរបស់លោក គឹកញ្ញា លី ស៊ាវមិញ អាយុ ២៣ឆ្នាំ ត្រូវបានចាប់ខ្លួន ខណៈពេលនាងទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីស្វែងរកឪពុក។[64] អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទ "ប្រើហិង្សាប្រឆាំងអ្នកកាន់កាប់អចលនវត្ថុដោយសុច្ចរិត ទាំងមិនដឹងថាគាត់មានប័ណ្ណកម្មសិទ្ធិ ឬដីនោះកំពុងមានជម្លោះ" តាមមាត្រា ២៥៣ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។ បន្ទាប់មកនៅល្ងាចថ្ងៃនោះ តំណាងក្រុមហ៊ុន ឃុន សៀ បានទាក់ទងទៅកូនប្រុសរបស់លោក ខេង ដើម្បីបន្តការចរចាអំពីដីជម្លោះនោះ។ លោក លី ស្រ៊ាខេង ត្រូវបានដោះលែងឲ្យនៅក្រៅឃុំកាលពីថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៤ ប៉ុន្តែ លី ស៊ាវមិញ នៅបន្តជាប់ឃុំដដែល។ ប្រសិនបើត្រូវបានផ្តន្ទាទោស ពួកគេប្រឈមនឹងការដាក់ពន្ធនាគារពី ៦ខែ ដល់២ឆ្នាំ និងពិន័យជាប្រាក់ពីមួយលានប្រាំសែនទៅពីរលានប្រាំសែនរៀល។[65]

ជាមួយគ្នានឹងសកម្មជនដីធ្លី សមាជិក និងថ្នាក់ដឹកនាំសហជីពក៏ងាយរងគ្រោះដោយការយាយីតាមផ្លូវតុលាការផងដែរ។ ក្នុងចំណោមសមាជិក និងមេដឹកនាំសហជីពចំនួន ៦២នាក់ដែល ម.ស.ម.ក បានគាំទ្រនៅឆ្នាំ២០១៤ មួយរយភាគរយគឺជាជនរងគ្រោះដោយការយាយីតាមផ្លូវតុលាការ។ ការចោទប្រកាន់ជាធម្មតាចោទថា ពួកគេបានញុះញង់ឲ្យកម្មករធ្វើកូដកម្ម បង្កចលាចល ឬបំផ្លាញទ្រព្យសម្បត្តិរបស់រោងចក្រ។

[61] ម.ស.ម.ក "អាដហុក អង្គការអភិវឌ្ឍន៍សំលេងសហគមន៍ ម.ស.ម.ក គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា ក្រុមការងារពិសេសសិទ្ធិលំនៅឋាន អំពាវនាវឲ្យមានការស៊ើបអង្កេតបន្ទាន់ និងឯករាជ្យចំពោះករណីយាយី និងការគំរាមកំហែងទាក់ទងទៅនឹងជម្លោះដីធ្លី" សេចក្តីថ្លែងការណ៍រួម (ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤) http://goo.gl/DYJLpq.

[62] គ្រួសារដែលប្រឈមនឹងការគំរាមកំហែង និងវាយប្រហារ (លេខ ៦៣៨)

[63] ឆាយ ចាន់នីដា "ភាគីជម្លោះរបស់ ឃុន សៀ ត្រូវបានឃុំខ្លួន" *ភ្នំពេញប៉ុស្តិ៍,* (ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤) http://goo.gl/lJOuBt.

[64] ម.ស.ម.ក "ការចាប់ខ្លួនតាមអំពើចិត្តក្នុងករណីបឹងកក់ ១" សេចក្តីថ្លែងការណ៍រួម (ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤), http://goo.gl/2o8lo5

[65] ដូចខាងលើ

ការយោយីតាមតុលាការទៅលើសកម្មជនសហជីព

កម្មករធ្វើការនៅរោងចក្រ អេស អិល (SL Garment) បានចាប់ផ្តើមធ្វើកូដកម្មកាលពីថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣។ ពួកគេបានទាមទារថ្លៃអាហារចំនួន ៣ដុល្លារក្នុងមួយថ្ងៃ និងត្រលប់មកអនុវត្តកាលវិភាគធ្វើការរយៈពេល ៨ម៉ោងរាល់ថ្ងៃ ជាជាងធ្វើការរយៈពេល ៩ម៉ោង ដែលខាងរោងចក្របានតម្រូវថ្មីៗនេះ។ បន្ថែមពីនេះទៅទៀត ពួកគេបានទាមទារឲ្យភាគីរោងចក្របើកប្រាក់ឈ្នួលធម្មតាក្នុងអំឡុងពេលដែលពួកគេធ្វើកូដកម្ម ព្រមទាំងផ្លាស់ប្តូរអ្នកគ្រប់គ្រងដែលទើបនឹងតែងតាំងថ្មី គឺលោក មាស សុថា និងទាហានដែលលោក មាស សុថា ជួលមកយាមនៅរោងចក្រ។ នៅអំឡុងខែសីហា ចំនួនកម្មករធ្វើកូដកម្មកើនឡើងដល់ ៦.០០០នាក់ ក្នុងចំណោមនោះមាន ២.៥០០នាក់ ជាសមាជិករបស់ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា។

កូដកម្មបានបន្តអស់រយៈពេលជាច្រើនខែ រហូតដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ បានបង្កឲ្យមានអំពើហិង្សាកើតឡើង។ ក្រុមអ្នកធ្វើកូដកម្មបានព្យាយាមដើរហែរក្បួនពីរោងចក្ររបស់ពួកគេសំដៅទៅផ្ទះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីជំរុញឲ្យរដ្ឋាភិបាលដោះស្រាយ ប៉ុន្តែពួកគេបានប្រឈមនឹងការបាញ់គ្រាប់កាំភ្លើងពីកងកម្លាំងប្រដាប់អាវុធតែប៉ុណ្ណោះ។ កម្លាំងនគរបាលបានបាញ់កាំភ្លើងទៅកាន់ហ្វូងក្រុមបាតុករដែលជាកម្មកររោងចក្រ អេស.អិល រាប់រយនាក់ ដែលបណ្តាលឲ្យស្លាប់ស្ត្រីលក់ដូរនៅតាមដងផ្លូវ និង ៩នាក់ទៀតត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយសាររងរបួសពីការបាញ់ប្រហារនោះ។ ក្រុមបាតុកប្រហែល៤០នាក់ ត្រូវបានចាប់ខ្លួននៅថ្ងៃនោះផងដែរ។

ម.ស.ម.ក បានផ្តល់ការគាំទ្រដល់៣ករណីដែលពាក់ព័ន្ធនឹងការតវ៉ានេះ។

ករណីទី១ [66] ពាក់ព័ន្ធទៅនឹងថ្ងៃចាប់ផ្តើមធ្វើកូដកម្មដំបូងពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០១៣ ។ នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣ រោងចក្រ អេស.អិល បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងសកម្មជនរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងកម្មករចំនួន ១៩នាក់[67] ដែលជាប់ពាក់ព័ន្ធក្នុងការតវ៉ានេះ។ ពួកគេត្រូវបានចោទប្រកាន់ពីបទ *"ធ្វើឲ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស"* តាមមាត្រា ៤១១ នៃក្រមព្រហ្មទណ្ឌ ដោយសារពួកគេ ត្រូវបានចោទថា ធ្វើឲ្យខូចម៉ាស៊ីនរោងចក្រ និងបិទរបងរោងចក្រដែលជាការរារាំងកម្មករមិនឲ្យចូលធ្វើការ។ នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ តុលាការបានបង្គាប់ឲ្យអ្នកទាំង ១៩នាក់នោះចូលធ្វើការវិញក្នុងរយៈពេល ៤៨ម៉ោង ហើយអ្នកទាំងនោះក៏ចូលធ្វើការតាមបង្គាប់។ ជនជាប់ចោទមិនទាន់ទទួលបានព័ត៌មានអ្វីបន្ថែមទៀតនោះទេ ហើយរឿងក្តីនេះកំពុងតែព្យួរ។

ករណីទី២[68] ពាក់ព័ន្ធនឹងបទល្មើសដែលបានប្រព្រឹត្តនៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៣ និងថ្ងៃទី

[66] សំនុំរឿងព្រហ្មទណ្ឌលេខ ២៤៥១

[67] ប៉ាវ ផាន់ណា, សាង រដ្ឋា, ឡាច ស៊ីកន, ឈួន ឈៀង, អ៊ូច នឿន, លាង សុខហៀង, ឡុង ឡឹប, លីស ស្រីម, ចាន់ ណារ័ត្ន, ហេង សារួន, កឹម សំអឿន, គង់ សុភ័ណ, ចែម សំអូន, ជួង រិទ្ធ, តេង រី, ណុច ស្តើង, ធូ ជីវ័ន្ត, រិត ស៊ីនឿន, ធាយ គីមស៊ី

[68] សំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៧៩

១ ខែ វិច្ឆិកា ឆ្នាំ២០១៣។ មនុស្ស ១២នាក់[69] រួមមានលោក អាត់ ធន់ ប្រធានសហជីព និងលោក ឯក សុភ័ក្រក្តី ជាលេខាធិការនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ត្រូវបានសាកសួរ[70] ពីករណី "*ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស*" តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ "*បទល្មើច*" និង តាមមាត្រា ៣៥៣ និង៣៥៦ និង "*បំផ្លិចបំផ្លាញដោយចេតនាមានស្ថានទម្ងន់ទោស*"។ ពួកគេត្រូវបានចោទថា បានបំផ្លិចបំផ្លាញឡានគូច និងឡានជីកទំនិញរបស់រោងចក្រ អេស. អិល ចំនួន ១៤គ្រឿង និងម៉ូតូរបស់កម្មករចំនួន ១៣គ្រឿង បំផ្លិចបំផ្លាញបង្អួចរោងចក្រ បំផ្លាញកុំព្យូទ័រចំនួន ១៤គ្រឿង និងកុំព្យូទ័រចំនួន ១៣គ្រឿងទៀតត្រូវបានលួច ព្រមទាំងសម្ភារៈដទៃទៀតរបស់រោងចក្រ។ ការចោទប្រកាន់ពីបទហិង្សាដោយចេតនានេះ គឺពាក់ព័ន្ធនឹងការធ្វើឲ្យកម្មករ និងបុគ្គលិកជនជាតិចិនរបស់រោងចក្ររងរបួស។ រោងចក្របានទាមទារសំណងពីសមាជិក សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាទាំង១២នាក់ ចំពោះការខូចខាតសម្ភារៈដែលមានតម្លៃសរុបដល់ទៅ ១៥.២១៤.២៨៤,៣៧ ដុល្លារសហរដ្ឋអាមេរិក អំឡុងពេលធ្វើកូដកម្ម និង ២.០១៨.៥៧៩ ដុល្លារសហរដ្ឋអាមេរិកសម្រាប់ថ្លៃសំណងដំងឺចិត្ត។ ការចោទនេះនៅមិនទាន់មានការចោទប្រកាន់ជាផ្លូវការនៅឡើយទេ ហើយចាប់ពីខែកុម្ភៈ ឆ្នាំ២០១៤មកករណីនេះមិនទាន់មានការវិវត្តនៅឡើយទេ ។

ករណីទី៣[71] ពាក់ព័ន្ធជាមួយបុគ្គលពីរនាក់ គឺលោក អាត់ ធន់ និង ប៉ាវ ផាន់ណា ជាសមាជិករបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា។ ពួកគេទាំងពីរនាក់ ត្រូវបានចោទពីបទ "*ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ*" និង "*ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស*"។ ករណីនេះត្រូវបានចោទថា កាលពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៣ លោក អាត់ ធន់ និង ប៉ាវ ផាន់ណា ញុះញង់ឲ្យកម្មកររើប្រើប្រាស់ ដំបងឆក់ ដុំថ្ម និងដំពាមកៅស៊ូ វាយទៅលើកម្មករដែលមិនចូលរួមកូដកម្ម ជាហេតុនាំឲ្យមនុស្សជាច្រើនរងរបួស។ កាលពីថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ លោក អាត់ ធន់ និង ប៉ាវ ផាន់ណា ត្រូវបានសាលាដំបូងរាជធានីភ្នំពេញកោះហៅទៅសាកសួរ និងដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការដោយមានលក្ខខណ្ឌមួយចំនួនដូចជា ពួកគេមិនត្រូវផ្លាស់ប្តូរលំនៅឋានដោយមិនមានការអនុញ្ញាតជាមុនពីចៅក្រមស៊ើបសួរ ហើយត្រូវតែចូលខ្លួននៅពេលដែលមានការកោះហៅពីចៅក្រមស៊ើបសួរ និងត្រូវបង្ហាញខ្លួននៅឯប៉ុស្តិ៍នគរបាលស្នឹងមានជ័យជារៀងរាល់ខែនៃសប្តាហ៍ទី៤។ លោក អាត់ ធន់ ត្រូវបានដាក់លក្ខខណ្ឌបន្ថែមដោយត្រូវបង់ប្រាក់ធានានៅក្រៅឃុំចំនួន ២៥.០០០ ដុល្លារសហរដ្ឋអាមេរិកទៅឲ្យសាលាដំបូងរាជធានីភ្នំពេញ ឲ្យបានមុនថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥។ នៅថ្ងៃ

[69] អាត់ ធន់៖ លោក ឯក សុភក្តី, ប៉ាវ ផាន់ណា, រិត នឿន, អ៊ូច នឿន, ចែម សំអូន, តេង រី, លាង សុខហៀង, ណុច ស្តើង, ឈួន ឈៀង, ឡាយ សីហ៊ន, និង អ៊ូ អ៊ាប។

[70] តុលាការបានកោះជនជាប់ចោទចំនួនពីរលើកឲ្យចូលទៅបំភ្លឺនៅតុលាការ ៖ លើកទី១ នៅខែធ្នូ ឆ្នាំ២០១៣ និងជាថ្មីម្តងទៀតនៅខែកុម្ភៈ ឆ្នាំ២០១៤។ តាមការពិត តេង រី និង ណុច ស្តើង ត្រូវបានសាកសួរម្តងរួចហើយកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៣ ខណៈពេលដែលលោក អាត់ ធន់, ឯក សុភ័ក្រក្តី, ប៉ាវ ផាន់ណា, រិត នឿន, អ៊ូច នឿន, ចែម សំអូន, លាង សុខហៀង, ឈួន ឈៀង ត្រូវបានសាកសួរនៅថ្ងៃទី៤ ទី៥ និង ទី៧ ខែកុម្ភៈ ឆ្នាំ២០១៤។

[71] សំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៧៣

ទី២១ ខែមេសា ឆ្នាំ២០១៤ សាលាដំបូងរាជធានីភ្នំពេញ បន្ថែមលក្ខខណ្ឌមិនឲ្យអ្នកទាំងពីរកាន់អាវុធ ឬជួបជុំជាមួយក្រុមណាមួយក្នុងគោលបំណងធ្វើសកម្មភាពដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ លោក អាត់ ធន់ ត្រូវរងការដាក់លក្ខខណ្ឌមួយទៀត គឺមិនត្រូវធ្វើអ្វីដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនៅជុំវិញបរិវេណសាលាដំបូងរាជធានីភ្នំពេញនោះទេ ដោយមិនត្រូវទៅរោងចក្រ អេស.អិល ឬក៏ជួបកម្មករនៅរោងចក្រនោះទេ។

នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ មេធាវីរបស់លោក អាត់ ធន់ បានដាក់ពាក្យទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីស្នើសុំឱ្យតុលាការបន្ថយប្រាក់ធានាពី ២៥.០០០ ដុល្លារសហរដ្ឋអាមេរិក មកត្រឹមតែ ១.០០០ ដុល្លារសហរដ្ឋអាមេរិកវិញ និងស្នើឲ្យតុលាការបញ្ឈប់ការត្រួតពិនិត្យមកលើកូនក្តីខ្លួន តែទោះជាយ៉ាងណាក៏ដោយ សំណើនេះត្រូវបានបដិសេធ។ នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០១៤ មេធាវី បានដាក់ពាក្យប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ ប៉ុន្តែសាលាឧទ្ធរណ៍បានបដិសេធ។ សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងអង្គការសង្គមស៊ីវិលមួយចំនួនបានរៀបចំយុទ្ធនាការអង្គាសថវិកា ដើម្បីយកទៅបង់ប្រាក់ធានា ហើយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ លោក អាត់ ធន់ បានបង់ប្រាក់ចំនួន ២១.០០០ ដុល្លារសហរដ្ឋអាមេរិក និង ១៦ លានរៀលទៅឲ្យតុលាការ។ នៅថ្ងៃដដែលនោះ លោក អាត់ ធន់ បានដាក់សំណើសុំឲ្យលុបចោលលក្ខខណ្ឌទាំងឡាយមកលើខ្លួន ប៉ុន្តែសំណើនោះត្រូវបានច្រានចោលនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤។

ថ្ងៃដដែលនោះ លោក អាត់ ធន់ ត្រូវបានតុលាការកោះហៅឲ្យចូលតុលាការនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៤ដើម្បីសាកសួរ។ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ លោក អាត់ ធន់ បានស្នើឲ្យការកោះហៅនេះលើកពេល ដោយហេតុថា លោកត្រូវចូលរួមសិក្ខាសិលាមួយនៅឯខេត្តកំពង់សោម ។ តុលាការបានសម្រេចពន្យារពេលហើយ លោកអាត់ ធន បានទៅកាន់តុលាការនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤ វេលាម៉ោង ២ និង៣០នាទីរសៀល។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ចៅក្រមស៊ើបសួរបានជូនដំណឹងទៅមេធាវីថា នីតិវិធីនៃការស៊ើបអង្កេតត្រូវបានបញ្ចប់ ។ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០១៤ ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីបានលើកឡើងថា អំពើហិង្សានៅមុខរោងចក្រ អេស.អិល បានប្រព្រឹត្តដោយកម្មកររោងចក្រ និងស្នើឲ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរបន្ថែម និងកោះហៅកម្មករដែលជាប់ពាក់ព័ន្ធនឹងអំពើហិង្សានេះមកសាកសួរ។ ម.ស.ម.ក មិនបានទទួលព័ត៌មាន ថាតើចៅក្រមស៊ើបសួរបានកោះហៅដែរឬអត់ និងមិនមានព័ត៌មាននៃការវិវឌ្ឍករណីនេះនៅឡើយទេ។ ករណីនេះនៅផ្អាកតែបន្តនៅឡើយ។

បន្ថែមលើករណីខាងលើនេះ តំណាងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា បានជួបជាមួយតំណាង អេស.អិល ដើម្បីចរចាកាលពីថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៣។ ការចរចារវាងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា និងរោងចក្រ អេស.អិល បានព្រមព្រៀងគ្នាដោយអ្នកគ្រប់គ្រងរោងចក្រ ព្រមបើកប្រាក់ឲ្យពាក់កណ្តាលនៃប្រាក់ឈ្នួលដែលគេអាចរកបានក្នុងអំឡុងពេលកូដកម្ម ហើយលោក មាស សុថា នឹងឈប់បំពេញការងារនៅរោងចក្រនេះ។

ក្រៅពីការយោយីតាមផ្លូវតុលាការប្រឆាំងនឹងបុគ្គល រាជរដ្ឋាភិបាលកម្ពុជាបានគម្រាមសហជីពមួយចំនួនធំនៅកម្ពុជាមានដូចជា សម្ព័ន្ធសហជីពកម្ពុជា("CATU") សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា ("CFSWF") សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា ("NIFTUC") និងសហជីពកម្មករសេរីនៃព្រះរាជាណាចក្រកម្ពុជា ("FTUWKC") ក្នុងការលុបចោលអាជ្ញាប័ណ្ណ ឬផ្អាកដំណើរការចុះបញ្ជី។[72]

ក្រុមហ៊ុនដែលមានអំណាចមួយចំនួនអាចបញ្ចុះបញ្ចូលរដ្ឋាភិបាល ក្នុងការកំហិតសិទ្ធិរបស់សហជីព។ ពីរខែបន្ទាប់ពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជាអះអាងថា សេរីភាពខាងការបង្កើតសមាគមត្រូវបានសហជីពរំលោភបំពាន[73] ណាង សុធី អនុប្រធានគណៈកម្មការប្រឹក្សាការងាររបស់រដ្ឋាភិបាលបានស្នើឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ពិចារណាឡើងវិញចំពោះហានៈរបស់កម្ពុជាក្នុងនាមជារដ្ឋហត្ថលេខីរបស់អនុសញ្ញាស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគមរបស់អង្គការពលកម្មអន្តរជាតិ។[74] ជាងនេះទៅទៀត មានពីរករណីដែលសមាជិកសហជីពពីរូបត្រូវបានបញ្ឈប់ពីការងារដោយខុសច្បាប់ព្រោះតែសកម្មភាពចូលរួមសហជីពរបស់ពួកគេ ផ្ទុយពីការពិតដែលសេរីភាពខាងការបង្កើតសមាគមត្រូវបានធានានៅក្នុងមាត្រា៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងមាត្រា២២ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។[75] ការអនុវត្តជាទូទៅមា្យងទៀតគឺ ក្រុមហ៊ុនទាមទារឲ្យសហជីពកម្មករសងដំងឺចិត្តតាមអំពើចិត្ត ជាញឹកញាប់មានចំនួនរាប់ពាន់ដុល្លារ បន្ទាប់ពីពួកគេរកឃើញថាមានទោស ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងពេលធ្វើការតវ៉ា។[76]

<u>អំពើហិង្សា និងការយោយីប្រឆាំងនឹងអ្នកការពារបរិស្ថាន និងសិទ្ធិដីធ្លីដែលប្រឆាំងនឹងការរំលោភដីធ្លី និងកាប់ឈើខុសច្បាប់</u>

---

[72] ម.ស.ម.ក "កំណត់ត្រាសង្ខេប៖ សេរីភាពក្នុងការបង្កើតសមាគមសម្រាប់សហជីព" (ខែមេសា ឆ្នាំ២០១៤) http://bit.ly/1pL0aJc

[73] សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) "អ្វីដែលគ្រប់គ្នាត្រូវដឹងអំពីអនុញ្ញាអង្គការពលកម្មអន្តរជាតិ លេខ៨៧ ស្តីពីសេរីភាពក្នុងការបង្កើតសមាគម និងសិទ្ធិក្នុងការធ្វើកូដកម្ម" សេចក្តីថ្លែងការណ៍ (ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤) http://bit.ly/NqmKqd

[74] ហ៊ិល ស្មើ និង អាឡិច រីលៀម "ម្ចាស់ក្រុមហ៊ុនស្នើសុំឲ្យលោក ហ៊ុន សែន លុបបំបាត់សិទ្ធិបង្កើតសហជីពរបស់កម្មករ" ខេមបូឌា ដេលី (ភ្នំពេញ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៤) http://bit.ly/1ctedPx

[75] នៅដើមខែមករា ឆ្នាំ២០១៤ មានសមាជិកយ៉ាងហោចណាស់ ៥០នាក់នៃសម្ព័ន្ធសហជីពចលនាកម្មករ និងសម្ព័ន្ធសហជីពកម្ពុជា("CATU") ត្រូវបានបណ្តេញចេញពីរោងចក្រជាច្រើននៅក្នុងតំបន់សេដ្ឋកិច្ចពិសេស មែនហាតាន ក្នុងខេត្តស្វាយរៀងដោយចោទប្រកាន់ថា បានចូលរួមក្នុងការធ្វើកូដកម្ម កាលពីខែធ្នូ ឆ្នាំ២០១៣។ សូមមើល មុំ គន្ធា និង ស៊ន ទីហាន "កម្មកររោងចក្រកាត់ដេរខេត្តស្វាយរៀង ត្រូវបានបណ្តេញចេញ និងព្យួរការងារ" *ភ្នំពេញប៉ុស្តិ៍* (ភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤) http://bit.ly/NNm5iU។ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ កម្មកររោងចក្រ JSD ត្រូវបានគេបណ្តេញចេញដោយសារប្រមូលស្នាមមេដៃក្នុងគោលបំណងបង្កើតសាខាសហជីពនៅថ្នាក់មូលដ្ឋាន។ សូមមើល មាន ដាវ៉ា "តុលាការចោទប្រកាន់តំណាងសហជីពថែមទៀតមុនកិច្ចប្រជុំជាមួយក្រុមហ៊ុនធំៗ" សារព័ត៌មាន *ខេមបូឌា ដេលី* (ភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤) http://bit.ly/1sU8j0u

[76] នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៤ មានសកម្មជនសហជីព ៦នាក់នៅស្រុកអង្គស្នួល ខេត្តកណ្តាល (សូមមើលខាងលើ) ត្រូវបានបង្គាប់ឲ្យបង់ប្រាក់សំណងដំងឺចិត្តចំនួន ១០០.០០០ ដុល្លារសហរដ្ឋអាមេរិកនៅក្រសួងមហាផ្ទៃ។

អ្នកការពារបរិស្ថាន និងអ្នកការពារសិទ្ធិដីធ្លីមានតួនាទីយ៉ាងសំខាន់ក្នុងការតស៊ូមតិលើសិទ្ធិដីធ្លីរបស់ប្រជាពលរដ្ឋ ការពារបរិស្ថាន ការពារធនធានធម្មជាតិ និងការពារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ នៅក្នុងឆ្នាំ២០១៤ ការយាយីអ្នកការពារបរិស្ថាន និងសិទ្ធិដីធ្លីរងការគម្រាមកំហែង និងជាគោលដៅនៃការប្រើអំពើហិង្សាមានចំនួនកាន់តែច្រើនឡើងៗ។ នៅក្នុងករណីមួយ លោក តាំង ទ្រី ដែលជាអ្នកកាសែតរាយការណ៍ទាក់ទងនឹងការជីកជញ្ជូនឈើខុសច្បាប់ និងផ្សព្វផ្សាយព័ត៌មានជាច្រើនករណីពាក់ព័ន្ធនឹងឧកញ៉ាដែលមានអំណាច ត្រូវបានសម្លាប់។ អតីតសមាជិកនៃសមាគមអ្នកកាសែតខ្មែរប្រជាធិបតេយ្យនៅខេត្តក្រចេះ ត្រូវបានគេរកឃើញសាកសពនៅក្បែររថយន្ត កាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៤។ ម.ស.ម.ក បានចងក្រងករណីចំនួន ៦ ពាក់ព័ន្ធនឹងការយាយីអ្នកការពារសិទ្ធិមនុស្ស ឬអ្នកកាសែតដែលធ្វើការលើករណីកាប់ឈើខុសច្បាប់ និងសិទ្ធិដីធ្លី។

ហានិភ័យដែលអ្នកការពារបរិស្ថាន និងការពារសិទ្ធិដីធ្លីជួបប្រទះ គឺបណ្តាលមកពីមន្ត្រីរបស់រដ្ឋ រួមមាន កងអាវុធហត្ថ និងបុគ្គលដែលមិនមែនជាតួអង្គរដ្ឋ និងកងសន្តិសុខឯកជន។ ពួកគេត្រូវឯការគម្រាមកំហែង នៅពេលចុះអង្កេតនៅមូលដ្ឋាន និងធ្វើការតស៊ូមតិប្រឆាំងនឹងក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្ស។

នៅក្នុងឆ្នាំ២០១៤ មានប្រជាពលរដ្ឋជាច្រើនកាន់តែព្រួយបារម្ភពីបញ្ហាបរិស្ថាន និងការកាប់ឈើខុសច្បាប់។ យោងតាមអង្គការក្លូបិលវីតនេស(Global Witness) បង្ហាញថាការរំលោភដីធ្លីបានបង្កឲ្យប៉ះពាល់ផ្ទៃដីចំនួន ២លាន ៥សែនហិចតា ដែលមានចំនួនស្មើនឹង ៧៦ភាគរយ នៃដីកសិកម្មនៅក្នុងប្រទេសកម្ពុជា។[77] ដីទាំងនោះភាគច្រើនត្រូវបានដកហូតចេញពីកសិករមូលដ្ឋាន ហើយលក់ឲ្យក្រុមហ៊ុនកសិកម្ម និងក្រុមហ៊ុនកៅស៊ូ។[78] តំបន់ផ្សេងទៀតនឹងរងការកាប់ព្រៃឈើ រួមទាំងឧទ្យានជាតិ និងព្រៃអភិរក្ស ដែលនេះនឹងធ្វើឲ្យព្រៃឈើនៅកម្ពុជាត្រូវវិនាសខ្ទេចខ្ទី។[79]

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិបានជំរុញឲ្យ "មានការពង្រឹងច្បាប់សិទ្ធិមនុស្ស និងបរិស្ថានដើម្បីចៀសវាងការរំលោភបំពានពីសំណាក់តួអង្គរដ្ឋ និងឯកជនទៅលើទីតាំងកន្លែងដែលសហគមន៍រស់នៅ និងប្រកបរបរចិញ្ចឹមជីវិត"។[80]

---

77 ក្លូបិលវីតនេស "យុទ្ធនាការស្តីពីអំពើពុករលួយក្នុងវិស័យប្រេង ឧស្ម័ន និងរ៉ែនៅក្នុងប្រទេសកម្ពុជា" http://bit.ly/1xki4aS.

78 ដូចខាងលើ

79 នាយកដ្ឋានព្រៃឈើ អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ "សេចក្តីសង្ខេបស្តីពីសារពើភ័ណ្ឌព្រៃឈើជាតិ (NFI) ៖ ប្រទេសកម្ពុជា (ខែមិថុនា ឆ្នាំ២០០៧), http://bit.ly/1BNdVuX

80 ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្ស ម៉ាហ្គារែត សេហ្គេចយ៉ា" (ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១) http://bit.ly/1GGZHN3

ករណីទំនប់ឆាយអារ៉ែង

មាតាធម្មជាតិ គឺជាអង្គការក្រៅរដ្ឋាភិបាលធ្វើការសហការណ៍ជាមួយជនជាតិដើមភាគតិច ជង ទាមទារឲ្យលុបចោលគម្រោងទំនប់អគ្គីសនីឆាយអារ៉ែង។ ទំនប់ដែលមានកម្លាំងភ្លើង១០៩មេកាវ៉ាត់ នឹងត្រូវធ្វើឡើងនៅភូមិជំនាប់ ខេត្តកោះកុង ហើយគ្រោងសាងសង់ដោយក្រុមហ៊ុនចិន ស៊ីណូហៃដ្រូ។ សមាជិកព្រឹទ្ធសភា ឯកឧត្តម ឡាវ ម៉េងឃីន និងភរិយា ជឹង សុភាព គឺជាក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុននេះ ហើយបានពាក់ព័ន្ធនឹងការបណ្តេញចេញដោយបង្ខំ និងការរំលោភសិទ្ធិមនុស្សផ្សេងទៀតកាលពីមុន។[81]

ទំនប់នេះគម្រោមកំហែងដល់ជីវៈចម្រុះ និងបង្កអស្ថិរភាពនៃប្រព័ន្ធអេកូឡូហ្ស៊ីនៅតំបន់ស្ទឹងអារ៉ែង ដែលជាផ្នែកមួយនៃតំបន់ព្រៃអភិរក្សជួរភ្នំក្រវ៉ាញ។ ការសាងសង់ទំនប់នឹងនាំឲ្យមានការបណ្តេញចេញជនជាតិដើមភាគតិច ជង ចំនួន៦០០គ្រួសារ ហើយនឹងបំផ្លាញដីចំនួន២ម៉ឺនហិចតា។ ក្រុមហ៊ុនពាណិជ្ជករសង្គម និងក្រុមអ្នកស្រាវជ្រាវខ្មែរ និងការអភិវឌ្ឍន៍ ដែលមានទីស្នាក់ការនៅទីក្រុងភ្នំពេញ បានធ្វើការស្ទង់មតិឃើញថា អ្នកភូមិប្រមាណ១.៣០០គ្រួសារនឹងត្រូវបណ្តេញចេញ។ ទំនប់នេះនឹងបំផ្លាញកេរ្តិ៍ដំណែលវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច ជង។ ក្រុមជនជាតិជង គឺជាក្រុមជនជាតិចុងក្រោយមួយរបស់កម្ពុជាដែលភាគច្រើនរស់នៅពឹងផ្អែកលើធនធានធម្មជាតិ។

កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ ក្រុមបុគ្គលិករបស់ក្រុមហ៊ុនស៊ីណូហៃដ្រូនៅប្រទេសកម្ពុជាបានមកដល់ភូមិជំនាប់ ដើម្បីរៀបចំកន្លែង មុនពេលវិស្វកររចិនមួយក្រុមធំមក គ្រោងនឹងស្រាវជ្រាវដោយយកសម្ភារៈសម្រាប់ខួងមកជាមួយផងដែរ។ អ្នកភូមិនៅទីនោះបានប្រឆាំងយ៉ាងខ្លាំងចំពោះវត្តមានរបស់គេ ព្រមទាំងបណ្តេញក្រុមការងារចេញពីភូមិ និងបិទផ្លូវមិនឲ្យពួកគេត្រឡប់ទៅទីនោះវិញ។ ដូច្នេះហើយទើបមានអន្តរាគមន៍ពីប៉ូលីស។

អ្នកភូមិបានបង្ហាញពីការមិនយល់ព្រមឲ្យអនុវត្តគម្រោង និងតតាំងជាមួយអភិបាលស្រុកពាក់ព័ន្ធនឹងប្រសាសន៍ដែលលោកលើកឡើងនៅក្នុងសារព័ត៌មាន មុននោះមួយថ្ងៃថា អ្នកភូមិបានយល់ព្រមចាកចេញពីតំបន់នោះ។

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៤ អ្នកតវ៉ា ១១នាក់ មកពីអង្គការមាតាធម្មជាតិបានបិទផ្លូវសារជាថ្មីចំពោះទស្សនកិច្ចរបស់អ្នកជំនាញចិន និងមន្ត្រីដែលពាក់ព័ន្ធនឹងគម្រោងនេះ។ ពួកគេទាំងនោះត្រូវបានឃុំខ្លួនមួយយប់រួមទាំងស្ថាបនិកអង្គការមាតាធម្មជាតិគឺ លោក អាឡិក ហ្គូនហ្សាឡេហ្ស ដេវីដសុន។ ពួកគេបានចុះហត្ថលេខានៅលើលិខិតមួយថា នឹងមិនពាក់ព័ន្ធជាមួយសកម្មភាព "ខុសច្បាប់" ហើយនឹងមិនចូលរួមបាតុកម្មនៅថ្ងៃក្រោយ ដើម្បីចៀសវាងពីការចោទប្រកាន់ រួចហើយក៏ត្រូវ

---

[81] ឧទាហរណ៍ ក្រុមហ៊ុនស៊ូកាគូជាក្រុមហ៊ុនឯកជនរបស់សមាជិកព្រឹទ្ធសភា ឯកឧត្តម ឡៅ មេងឃីន និងភរិយា ជឹង សុភាព ដែលជួលតំបន់ ក្នុងសង្កាត់បឹងកក់ រាជធានីភ្នំពេញ ជាកន្លែងដែលប្រជាជនចំនួន៣.០០០ គ្រួសារត្រូវបានបណ្តេញចេញ។ ផនបុប្ផា និង ស្យូមប៉ារ៉ាតជ័រ "អ្នកភូមិបឹងកក់ដែលត្រូវបានបណ្តេញចេញស្នើឲ្យសាលារាជធានីភ្នំពេញផ្តល់សំណងសមរម្យ" *ខេមបូឌាដេលី* (ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣) http://goo.gl/Fzq0Ft

បានដោះលែង។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៤ អាជ្ញាធរអន្តោប្រវេសន៍កម្ពុជា បាននិរទេសលោក អាឡិក ហ្គូនហ្សា ឡេហ្ស ដេរីដសុន បន្ទាប់ពីក្រសួងមហាផ្ទៃសម្រេចមិនបន្តទិដ្ឋាការរបស់លោក អាឡិក ដែលបានអស់សុពលភាពរយៈពេលបីថ្ងៃមកហើយ។ លោក ហ្គូនហ្សាឡេហ្ស ដេរីដសុន មានសិទ្ធិស្នាក់នៅក្នុងប្រទេសកម្ពុជាដោយស្របច្បាប់រយៈពេល ២៧ថ្ងៃបន្ទាប់ពីទិដ្ឋការអស់សុពលភាព ដោយគ្រាន់តែត្រូវបង់ប្រាក់ពិន័យ។ ការនិរទេសរបស់គាត់ត្រូវបានមើលឃើញជាទូទៅថា ជាវិធានការតបតទៅលើសហគមន៍នៅតំបន់ស្ទឹងអារ៉ែង ចំពោះយុទ្ធនាការប្រឆាំងនឹងការសាងសង់ទំនប់ធាយអារ៉ែងនោះ។[82]

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

នៅក្នុងឆ្នាំ២០១៤ អ្នកការពារសិទ្ធិមនុស្សបានមើលឃើញថា បរិយាកាសការងាររបស់ពួកគេត្រូវបានរឹតបន្តឹងជាពិសេសតាមរយៈការរឹតត្បិតសិទ្ធិសេរីភាពខាងការជួបប្រជុំ និងខាងការបញ្ចេញមតិ និងបន្តទទួលរងការយាយីពីអាជ្ញាធររដ្ឋ និងក្រុមហ៊ុនឯកជន។

ដោយពិចារណាទៅលើស្ថានភាពបច្ចុប្បន្ន ដូចបានរៀបរាប់ខាងលើ ម.ស.ម.ក សូមស្នើអនុសាសន៍ដូចខាងក្រោមជាក់ជូនទៅរដ្ឋាភិបាល ៖

- ធានាថា មន្ត្រីអនុវត្តច្បាប់ទាំងអស់ដែលដាក់ឲ្យរក្សាសន្តិសុខនៅពេលធ្វើបាតុកម្ម បានទទួលការបណ្តុះបណ្តាលផ្នែកសិទ្ធិមនុស្ស និងគោរពតាមគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើកម្លាំងប្រដាប់អាវុធ និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌របស់មន្ត្រីអនុវត្តច្បាប់
- ដាក់ពង្រាយកងកម្លាំងយោធាតែក្នុងស្ថានភាពធ្ងន់ធ្ងរពាក់ព័ន្ធនឹងបញ្ហាសន្តិសុខជាតិ និងបញ្ឈប់ការប្រើកងកម្លាំងសន្តិសុខខណ្ឌឲ្យយាមកាមនៅកន្លែងធ្វើការតវ៉ា
- ធានាឲ្យមានការស៊ើបអង្កេតបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ហើយផ្តន្ទាទោសជនដៃដល់ ដោយស្តាប់នឯករាជ្យ និងមិនលម្អៀង ធ្វើរបាយការណ៍អំពីការប្រើប្រាស់កម្លាំងហួសប្រមាណដោយមន្ត្រីអនុវត្តច្បាប់ និងកងសន្តិសុខឯកជនដែលរដ្ឋបានជួលមកបម្រើការ ព្រមទាំងដាក់បង្ហាញលទ្ធផលនោះជាសាធារណៈ
- ធានាផ្តល់សំណងសមរម្យដល់ជនរងគ្រោះ និងធានាថា រាល់ករណីរំលោភបំពាន និងអំពើហិង្សាប្រឆាំងនឹងអ្នកសារព័ត៌មាន សកម្មជននយោបាយ អ្នកនយោបាយគណបក្សជំទាស់ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សមាជិកសហជីព និងអ្នកការពារសិទ្ធិមនុស្សផ្សេងទៀត មានការស៊ើបអង្កេតត្រឹមត្រូវ ហើយជនដៃដល់ត្រូវបាននាំយកមកផ្តន្ទាទោសដោយមិនគិតពីឋានៈរបស់ជននោះ

[82] ម.ស.ម.ក សកម្មជននៅសហគមន៍មូលដ្ឋានក្នុងខេត្តកោះកុងស្ថិតក្នុងភាពហានិភ័យបន្ទាប់ពីការបណ្តេញចេញសហការីជនជាតិបរទេស សេចក្តីប្រកាសព័ត៌មាន (ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥) http://goo.gl/hDAqGV

- ធានាការគោរពសិទ្ធិសេរីភាពខាងការជួបប្រជុំ ហើយបញ្ឈប់ជាផ្លូវការនូវការហាមប្រាមតាមអំពើចិត្តទាំងស្រុងចំពោះការជួបប្រជុំជាសាធារណៈ
- បញ្ឈប់នូវការអនុវត្តដែលបង្ខំឲ្យអ្នកការពារសិទ្ធិមនុស្ស និងប្រជាពលរដ្ឋដែលអនុវត្តសិទ្ធិសេរីភាពមូលដ្ឋានខាងការបញ្ចេញមតិ សេរីភាពខាងការជួបប្រជុំ ចុះហត្ថលេខាលើកិច្ចសន្យាដែលមានការរឹតត្បិតដល់សិទ្ធិរបស់ពួកគេជាថ្នូរទៅនឹងការដោះលែង ឬចៀសវាងការចោទប្រកាន់ ព្រមទាំងលុបចោលនូវលិខិតទាំងឡាយណាដែលបានចុះហត្ថលេខានាពេលកន្លងមក
- អនុវត្តជាបន្ទាន់នូវការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ស្របទៅតាមគោលការណ៍ទីក្រុង ប៉ារីស
- បញ្ឈប់ការយាយីតាមប្រព័ន្ធតុលាការទៅលើអ្នកការពារសិទ្ធិមនុស្ស សកម្មជននយោបាយ និងអ្នកនយោបាយគណបក្សជំទាស់ ព្រមទាំងដោះលែងជាបន្ទាន់ដោយគ្មានលក្ខខ័ណ្ឌដល់អ្នកកំពុងជាប់ឃុំ ដែលត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសដោយសារហេតុផលនយោបាយ
- ឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់អ្នករាយការពិសេសអំពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋ (នៅឆ្នាំ២០១២ អ្នករាយការណ៍ពិសេសបានសរសេរសំ ណើមកកាន់រដ្ឋាភិបាលដើម្បីមកធ្វើទស្សនកិច្ចផ្លូវរដ្ឋមកកម្ពុជា)[83] ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងកញ្ញា ឆាយ ឈុនលី មន្ត្រីសម្របសម្រួលគម្រោងការពារសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ (+៨៥៥)១៧ ៥២៨ ០២១ ឬ តាមរយៈអ៊ីមែល ៖ chhunly.chhay@cchrcambodia.org ឬ លោកស្រី ម៉ាតា រីហ្គី ទីប្រឹក្សា តាមរយៈទូរសព្ទ ៖ (+៨៥៥)១៣ ៥៩០ ៦៧១ ឬ អ៊ីមែល ៖ marta.riggio@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

[83] អង្គការសហប្រជាជាតិស្តីពីសិទ្ធិមនុស្ស "ទស្សនកិច្ចផ្លូវរដ្ឋ" លេខ២